ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ

NATION RELIGION KING

ធនាគារជាតិ នៃ កម្ពុជា

NATIONAL BANK OF CAMBODIA

# របាយការណ៍ប្រចាំឆ្នាំ២០០៦

# និង

# ទិសដៅការងារឆ្នាំ២០០៧

# អារម្ភកថា

ឆ្នាំ២០០៦ ត្រូវបានសម្គាល់ដោយការរីកចម្រើនឡើងវិញជាលំដាប់នៃសេដ្ឋកិច្ចពិភពលោក បន្ទាប់ពីមានវិបត្តិហិរញ្ញវត្ថុ និងរូបិយវត្ថុ ឆ្នាំ១៩៩៧ ដែលទ្រទ្រង់ដោយសមិទ្ធផលវិស័យឯកជនសំខាន់ៗ ដូចជា លក្ខខណ្ឌអនុគ្រោះនៅក្នុង ទីផ្សារហិរញ្ញវត្ថុអន្តរជាតិ និងកំណើនតម្រូវការក្នុងស្រុក ។ ទោះបីជាថ្លៃប្រេងដែលបានកើនឡើងយ៉ាងរហ័សចាប់តាំងពីដើម ឆ្នាំ២០០៤មក បានធ្វើឱ្យនឹកឃើញឡើងវិញនូវផលវិបាកនៃសេដ្ឋកិច្ចពិភពលោក ជាលទ្ធផលនៃវិបត្តិថ្លៃប្រេងក្នុងអំឡុងទសវត្សទី៧០ក៏ដោយ ក៏ការកើតឡើងវិញជាថ្មីនៃវិបត្តិប្រេងនោះមិនទំនងជាអាចមានឡើយនៅក្នុងបរិយាកាសសេដ្ឋកិច្ច ពិភពលោកបច្ចុប្បន្ន ។ កំណើនសេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០០៦ ត្រូវបានប៉ាន់ស្មានថានឹងមានកម្រិត ៥,១% ទោះបីជាថ្លៃ ប្រេងមានកំណើនខ្ពស់ ហើយភាពតានតឹងនៅតំបន់មួយចំនួនមានការកើនឡើងនិងមានគ្រោះធម្មជាតិផងក្តី ។ កំណើន សេដ្ឋកិច្ចនៅសហរដ្ឋអាមេរិក និងអឺរ៉ុប ត្រូវបានប៉ាន់ស្មានថា នឹងកើនឡើងដល់ ៣,៣% និង ២,៦% រៀងៗខ្លួន ក្នុងឆ្នាំ ២០០៦ ឯប្រទេសជប៉ុននឹងមានកំណើនប្រហែល ២,៧% ប្រទេសចិននិងឥណ្ឌានឹងមានកំណើនក្នុងកម្រិតពី ៨% ទៅ ១០% ហើយកំណើនសេដ្ឋកិច្ច អាស៊ានត្រូវបានប៉ាន់ស្មានថា កើន ៥,៤% ។ ជាក់ស្តែង មូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចពិភពលោកជាទូទៅត្រូវ បានពង្រឹងបន្ថែមទៀត ហើយនិន្នាការ និរន្តរភាពនៃកំណើនសេដ្ឋកិច្ចក៏បានកើតឡើងដែរ ខណៈដែលបណ្តាប្រទេសជាច្រើន ជា ពិសេស ប្រទេសដែលមាន សេដ្ឋកិច្ចទីផ្សារកំពុងងើបឡើងបានធ្វើកំណែទម្រង់រចនាសម្ព័ន្ធចាំបាច់ប្រកបដោយជោគជ័យ ហើយដូច្នេះអាចមាន លទ្ធភាពទទួលបានអត្ថប្រយោជន៍ពីសកលភាវូបនីយកម្មសេដ្ឋកិច្ចពិភពលោក ។ ពិតណាស់ ឱនភាពនៃគណនី ចរន្តរបស់ សហរដ្ឋអាមេរិកបន្តស្ថិតនៅជាកង្វល់ដ៏សំខាន់មួយ ដែលអាចបង្កឥទ្ធិពលអវិជ្ជមានដល់ស្ថានភាពសេដ្ឋកិច្ចពិភព លោក ។

កម្ពុជាក៏ជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើន ដែលទទួលអត្ថប្រយោជន៍ពីកំណែទម្រង់ និងកំណែតម្រូវរចនាសម្ព័ន្ធនេះផងដែរ ។ រាជរដ្ឋាភិបាលកម្ពុជាដឹងច្បាស់ហើយថា ការឈានទៅមុខតាមវិធានការកំណែ ទម្រង់រចនាសម្ព័ន្ធ គឺជាគន្លឹះសម្រាប់ជំរុញភាពប្រកួតប្រជែងសេដ្ឋកិច្ច ការធ្វើឱ្យសម្រេចបាននូវកំណើនដ៏ធំធេង និងការជំរុញបន្ថែមទៀតនូវ ការកាត់បន្ថយភាពក្រីក្រ ទន្ទឹមនឹងការខិតខំប្រឹងប្រែងជំរុញលទ្ធិប្រជាធិបតេយ្យ សន្តិភាពនិងស្ថិរភាព ។ ការអភិវឌ្ឍ សេដ្ឋកិច្ចនាពេលថ្មីៗនេះ បានឆ្លុះបញ្ចាំងនូវការខិតខំប្រឹងប្រែងធ្វើកំណែទម្រង់ទាំងនោះ ។

ទន្ទឹមនឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចប្រុងប្រយ័ត្ន សេដ្ឋកិច្ចជាតិបានសម្រេចវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដែល នៅឆ្នាំ២០០៥ មានកំណើនរហូតដល់ ១៣,៤% ។ ការប៉ាន់ស្មានកំណើនយ៉ាងប្រយ័ត្នប្រយែងសម្រាប់ឆ្នាំ២០០៦ គឺ ៩,៥% ដោយគិតទៅដល់ហានិភ័យពាក់ព័ន្ធនឹងថ្លៃប្រេងខ្ពស់ ។ អតិផរណាប្រចាំឆ្នាំបានថយចុះចំនួន ៣,៩% ពីកម្រិត ៦,៧% មក ២,៨% នៅខែធ្នូ ឆ្នាំ២០០៦ ក្នុងអំឡុងពេលដូចគ្នាកាលពីឆ្នាំមុន ។ ការថយចុះនេះបណ្តាលមកពីការថយចុះថ្លៃម្ហូបអាហារ រួមនឹងថ្លៃដឹកជញ្ជូនដែលបានថយចុះក្នុងកម្រិតមួយដែរ ។ ក្នុងអំឡុងឆ្នាំនេះ ប្រាក់រៀល មានស្ថិរភាពជាទូទៅ ។ ប្រាក់រៀល ធៀបនឹងដុល្លារអាមេរិកបានឡើងថ្លៃ ១,៤% ធៀបនឹងការចុះថ្លៃ ២,១% នាឆ្នាំមុន ។ ដោយសារភាពបើកចំហនៃសេដ្ឋកិច្ច កម្ពុជា ស្ថិរភាពជាទូទៅនៃអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកជា

កត្តាគន្លឹះមួយក្នុងចំណោមកត្តាគន្លឹះដទៃទៀត សម្រាប់ទប់ស្កាត់ការឡើងថ្លៃទំនិញក្នុងស្រុក ។ ចំពោះប្រតិបត្តិការសេដ្ឋកិច្ចអន្តរជាតិវិញការអភិវឌ្ឍបច្ចុប្បន្នបានបង្ហាញថាទោះបីជាមានការលុបប្រព័ន្ធកូតាលើការនាំចេញសម្លៀកបំពាក់របស់ប្រទេសកម្ពុជាក៏ដោយក៏ស្ថិរភាពប្រតិបត្តិការ សេដ្ឋកិច្ចអន្តរជាតិហាក់បីដូចជាពុំមានហានិភ័យគួរឱ្យកត់សម្គាល់ខ្លាំងឡើយ ។ ទុនបម្រុងអន្តរជាតិបានបន្តកើនឡើង និង ផ្តល់ការគាំទ្រសម្រាប់បំពេញតម្រូវការ នៃការនាំចូលដែលបានកើនឡើងថែមទៀត ។ នៅចុងឆ្នាំ២០០៦ ទុនបម្រុងអន្តរជាតិ បានកើនឡើងចំនួន ១៨១,៥លានដុល្លារអាមេរិក ដែលធានាឱ្យការនាំចូលបានប្រមាណ ២,៩ ខែ ។ ទន្ទឹមនឹងនេះដែរ បំណុលបរទេសត្រូវបានរក្សាក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន ។

ស្ថានភាពវិស័យធនាគារ និងហិរញ្ញវត្ថុក៏បានបង្ហាញពីសញ្ញាវិជ្ជមានផងដែរ ។ ប្រតិបត្តិការធនាគារ មានការរីកចម្រើនជាបន្តបន្ទាប់ ខណៈដែលអន្តរការិយកម្មហិរញ្ញវត្ថុបានកើនឡើង ដោយឆ្លុះបញ្ចាំងពីស្ថិរ ភាពហិរញ្ញវត្ថុ និងការរីក ចម្រើននៃសេវាហិរញ្ញវត្ថុ ដែលត្រូវបានជំរុញតាមរយៈ ការអនុវត្តកំណែទម្រង់ច្បាប់និងស្ថាប័ន នៅក្រោមចក្ខុវិស័យនិងផែន ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ។ រូបិយវត្ថុទូទៅ (M2) ធៀបនឹង ផ.ស.ស បានកើនឡើងពី ១២,៨% នៃ ផ.ស.ស ឆ្នាំ២០០០ ទៅ ២៤,៣% នៃ ផ.ស.ស ក្នុងខែធ្នូ ឆ្នាំ២០០៦ ខណៈដែលស្ថិរភាពថ្លៃរក្សាបាននូវលំនឹង ពោល គឺជាការរីកចម្រើននៃរចនាសម្ព័ន្ធយ៉ាងសំខាន់ ។ ជាមួយគ្នានេះដែរ ឥណទានចំពោះវិស័យឯកជនបានកើនឡើងពី ៦,៥%នៃ ផ.ស.ស នាឆ្នាំ២០០០ ទៅប្រមាណ ១២,៧% នៃ ផ.ស.ស ក្នុងខែធ្នូ ឆ្នាំ២០០៦ ។ លើសពីនេះទៅទៀត ដោយផ្អែកលើ មូលដ្ឋានភាពគ្រប់គ្រាន់នៃដើមទុន ឥណទាន មិនដំណើរការ កម្រិតចំណូល និងសាច់ប្រាក់ងាយស្រួល ស្ថានភាពនិងប្រតិបត្តិ ការហិរញ្ញវត្ថុជារួមរបស់វិស័យធនាគារក្នុង អំឡុងឆ្នាំនេះ ទទួលបាននូវលទ្ធផលគួរជាទីពេញចិត្ត ។

ចំណែកការអភិវឌ្ឍវិស័យហិរញ្ញវត្ថុវិញ ធនាគារជាតិនៃកម្ពុជាបានជំរុញបន្ថែមទៀតនូវកំណែទម្រង់ រចនាសម្ព័ន្ធក្នុងវិស័យហិរញ្ញវត្ថុនិងធនាគារដើម្បីទទួលបាននូវភាពរឹងមាំ ព្រមទាំងសន្ទុះក្នុងប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយចីរភាព សំដៅទ្រទ្រង់ការអនុវត្តនយោបាយរូបិយវត្ថុប្រកបដោយប្រសិទ្ធភាព និងដើម្បីពង្រីកដំណើរការអន្តរការិយកម្ម ។

ដើម្បីលើកស្ទួយកិត្យានុភាពរបស់ប្រទេសកម្ពុជាលើឆាកអន្តរជាតិ សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មត្រូវបានដាក់ជូនរដ្ឋសភារួចហើយ ។ កម្ពុជាក៏បានចូលជាសមាជិកពេញសិទ្ធិនៃក្រុមអាស៊ី ប៉ាស៊ីហ្វិក (APG) ស្តីពីការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម កាលពីខែឧសភា ឆ្នាំ២០០៥ ។ បច្ចុប្បន្ននេះ កម្ពុជាកំពុង ត្រៀមលក្ខណៈទទួលក្រុមវាយតម្លៃអញ្ញមញ្ញ (Mutual evaluation) ដែលនឹងមកដល់ប្រទេសកម្ពុជា ដើម្បីវាយតម្លៃអំពី ស្ថានភាពប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នៅខែកុម្ភៈ ឆ្នាំ២០០៧ ខាងមុខនេះ ។

ក្នុងការអនុវត្តមុខងារ-ភារកិច្ចដែលបានកំណត់ដោយច្បាប់ សំដៅទទួលបានស្ថិរភាពហិរញ្ញវត្ថុ ធនាគារជាតិ នៃកម្ពុជា បានបន្តតាមដានប្រព័ន្ធហិរញ្ញវត្ថុក្នុងស្រុក ដើម្បីកំណត់អត្តសញ្ញាណភាពទន់ខ្សោយខាងផ្នែករចនាសម្ព័ន្ធនានា ក្នុងខណៈរក្សា ទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកផ្តល់សេវាកម្មធនាគារ និងបណ្តាភាគីពាក់ព័ន្ធនៅក្នុងវិស័យឯកជន ក្នុងគោលបំណងរួមគ្នាធ្វើឱ្យ កាន់តែប្រសើរឡើងនូវប្រសិទ្ធភាព និងអន្តរការិយកម្មធនាគារ ។ នៅក្នុងបរិការណ៍នេះ ការងារត្រួតពិនិត្យធនាគារបានបន្ត ផ្តោតការយកចិត្តទុកដាក់ទៅលើការធានាឱ្យប្រព័ន្ធធនាគាររឹងមាំ ។ សមត្ថភាពរបស់ធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តការ ត្រួតពិនិត្យធនាគារដល់ទីកន្លែង និងតាមឯកសារ ត្រូវបាន បង្កើនឡើងជាប្រចាំ ។ គ្រប់ធនាគារទាំងអស់ត្រូវស្ថិតនៅក្រោមការ ត្រួតពិនិត្យដល់ទីកន្លែង យ៉ាងហោចណាស់មួយដងជា រៀងរាល់២ឆ្នាំ ។

ការបង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទានដែលផ្លាស់ប្តូរព័ត៌មានឥណទានអវិជ្ជមាន ទាក់ទងទៅនឹងកូនបំណុល របស់ធនាគារ ក្នុងចំណោមធនាគារសមាជិកទាំងឡាយ ក៏ត្រូវបានសម្រេចតាមគោលដៅកំណត់ និងបានចាប់ផ្តើមធ្វើ ប្រតិបត្តិការលើមូលដ្ឋានជកពិសោធន៍ ចាប់តាំងពីខែសីហាឆ្នាំនេះមកម្ល៉េះ ។ អត្ថប្រយោជន៍នៃប្រព័ន្ធនេះត្រូវបានរំពឹងថា នឹងទទួលបានតាមរយៈការកើនឡើងនៃឥណទាន ជាពិសេសឥណទានចំពោះកូនបំណុលតូចៗ និងនៅក្នុងការកាត់បន្ថយ ចំណាយរបស់អ្នកខ្ចីប្រាក់ព្រមទាំងការកាត់បន្ថយហានិភ័យឥណទាន ក្នុងប្រព័ន្ធធនាគារ ។

នៅក្នុងការខិតខំកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាលក៏បានយល់ផងដែរថា មូលដ្ឋានផលិតកម្ម ត្រូវតែអភិវឌ្ឍទូទាំង ប្រទេស ពីទីក្រុងរហូតដល់ជនបទដាច់ស្រយាល ។ នៅក្នុងបរិការណ៍នេះ ការផ្គត់ផ្គង់យ៉ាងគ្រប់គ្រាន់នៃសេវាមីក្រូហិរញ្ញវត្ថុ ត្រូវបានចាត់ទុកថា ជាមធ្យោបាយសំខាន់សម្រាប់ផ្តួចផ្តើម និងទ្រទ្រង់ការអភិវឌ្ឍជនបទ ។ ឆ្នាំ២០០៦ ត្រូវបានប្រកាសថា ជាឆ្នាំមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ហើយចាប់តាំងពីដើមឆ្នាំមក សន្និសីទនិងសិក្ខាសាលាស្តីពីមីក្រូហិរញ្ញវត្ថុត្រូវបានប្រារព្ធធ្វើ ឡើងជាបន្តបន្ទាប់ ក្នុងគោលបំណងធ្វើឱ្យកាន់តែ ប្រសើរឡើងនូវប្រសិទ្ធភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងជំរុញការយល់ដឹង ច្បាស់ជាងមុនរបស់សាធារណជនទៅលើវិស័យនេះ ហើយដូច្នេះ សាធារណជនអាចប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុកាន់តែទូលំ ទូលាយឡើង ។ វិស័យមីក្រូហិរញ្ញវត្ថុក៏ត្រូវការយ៉ាងចាំបាច់នូវការឧបត្ថម្ភគាំទ្រយ៉ាងពេញទំហឹងពីអាជ្ញាធរជាបន្តទៅទៀត នាអនាគត ដើម្បីបង្កលក្ខណៈឱ្យវិស័យនេះកាន់តែអភិវឌ្ឍយ៉ាងទូលំទូលាយគ្រប់ទិសទី ។

ភាពចាំបាច់ក្នុងការលើកកម្ពស់ក្របខ័ណ្ឌគតិយុត្តនៅក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ ក៏ត្រូវបានទទួលការយកចិត្តទុក ដាក់ជាច្រើនផងដែរ ក្នុងឆ្នាំ២០០៦ នេះ ។ ស្តង់ដារបទបញ្ញត្តិត្រូវបានកែលំអ ហើយបទបញ្ញត្តិធនាគារថ្មីៗបន្ថែមទៀត ក៏ត្រូវ បានដាក់ឱ្យប្រើប្រាស់សំដៅពង្រឹងប្រព័ន្ធធនាគារ រួមមានទាំងវិធានការពាក់ព័ន្ធនឹងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ផងដែរ ដែលត្រូវប្រើប្រាស់មួយរយៈ ខណៈរង់ចាំការអនុម័តច្បាប់នេះពីសំណាក់ស្ថាប័ននីតិបញ្ញត្តិ ។ សេចក្តីព្រាងនៃច្បាប់នេះ ក៏មានចែងផងដែរអំពីការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ។ ទន្ទឹមនោះ ការងារគតិយុត្តខ្លះទៀត មានគោលបំណង ពង្រីកសកម្មភាពធនាគារ និងអាជីវកម្មពាក់ព័ន្ធផ្សេងៗ ដូចជា

ការរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់សកម្មភាពភតិសន្យា ដែល នឹងកាត់បន្ថយកង្វះសេវាហិរញ្ញវត្ថុនៅក្នុងទីផ្សារ និង បន្ថែមប្រភពហិរញ្ញប្បទានថ្មី ជាពិសេស ចំពោះសហគ្រាសធុនតូច និងមធ្យម ដែលពុំសូវមានលទ្ធភាព ទទួលបាន នូវឥណទានធនាគារ ។

ការអភិវឌ្ឍប្រព័ន្ធទូទាត់និងផាត់ទាត់នៅកម្ពុជាឱ្យមានដំណើរការប្រសើរជាងមុន ក៏ទទួលបាននូវវឌ្ឍនភាពមួយកម្រិតទៀតដែរ ។ បន្ទាប់ពីមានការអនុម័តច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់រួចប្រកាសចំនួន ៣ ត្រូវបានដាក់ឱ្យអនុវត្ត និងសេចក្តីព្រាងប្រកាសមួយទៀតកំពុងត្រូវបានរៀបចំ ។ លើសពីនេះទៀតការអប់រំផ្សព្វផ្សាយក៏ ត្រូវបានធ្វើឡើងតាមរយៈសិក្ខាសាលាមួយចំនួន សំដៅលើកកម្ពស់ការយល់ដឹងរបស់សាធារណជនព្រមទាំងវិស័យឯកជន អំពីរបៀបចេញផ្សាយ និងប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុថ្មីនៅក្នុងមុខរបរពាណិជ្ជកម្ម និងសេវាកម្ម ព្រមទាំងរបៀបទូទាត់ សងប្រាក់ទំនើបដោយមិនប្រើសាច់ប្រាក់ផងដែរ ។

សមិទ្ធផលគួរជាទីចាប់អារម្មណ៍មួយទៀត ក្នុងអំឡុងឆ្នាំ២០០៦ គឺការធ្វើបច្ចុប្បន្នកម្ម "ចក្ខុវិស័យនិងផែនការ អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០១-២០១០" ទៅជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥" ។ ក្នុង លក្ខណៈជាផែនការរយៈកាលវែង ការធ្វើបច្ចុប្បន្នកម្មចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុត្រូវបានចាត់ទុកថា ជា ទង្វើចាំបាច់ដើម្បីឆ្លុះបញ្ចាំងនូវវឌ្ឍនភាពថ្មីៗ បម្រែបម្រួលលំដាប់លំដោយ ការងារថ្មីៗទៀតដែលត្រូវអនុវត្តព្រមទាំងលក្ខខណ្ឌ នានាសម្រាប់ទ្រទ្រង់ស្ថាប័នដែលទទួលប្រតិបត្តិ ហើយដូចនេះ នឹងមានលទ្ធភាពផ្តល់នូវសន្ទុះមួយខ្ពស់ជាងមុន ចំពោះកំណែ ទម្រង់វិស័យហិរញ្ញវត្ថុក្នុងរយៈពេលឆ្នាំ២០០៦-២០១៥ ។

ពាក់ព័ន្ធនឹងការរៀបចំផ្ទៃក្នុង ធនាគារជាតិនៃកម្ពុជាបានឈានទៅមុខជាលំដាប់ជាមួយនឹងការ ធ្វើកំណែទម្រង់រចនាសម្ព័ន្ធចាំបាច់ដែលបានកំណត់ឡើង ដោយមានការចូលរួមជាយោបល់ពីសំណាក់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិសំខាន់ៗក៏ដូចជា ការសិក្សាលើបទពិសោធន៍និងការអនុវត្តល្អៗរបស់ធនាគារកណ្តាលដទៃទៀត ។ នៅក្នុងបរិការណ៍នេះ មុខងារចម្បងៗ មួយចំនួនរបស់ធនាគារជាតិនៃកម្ពុជាត្រូវបានកែលំអ ។ ប្រព័ន្ធសវនកម្មផ្ទៃក្នុងត្រូវបានពង្រឹងដោយមានការយកចិត្តទុក ដាក់ ជាពិសេសទៅលើការរៀបចំឱ្យប្រសើរឡើងនូវឯកសារ បទបញ្ញត្តិនានា ពាក់ព័ន្ធនឹងសកម្មភាពនិងគោលនយោបាយ សវនកម្ម ការបណ្តុះបណ្តាលសវនករ និងការលើកកម្ពស់រចនាសម្ព័ន្ធចាត់តាំងនៃអគ្គាធិការដ្ឋាន។ លើសពីនេះទៀតការិយាល័យគតិយុត្តត្រូវបានបង្កើតឡើងដែលទទួលភារៈសិក្សាពិនិត្យនិង ចូលរួមក្នុងការងារគតិយុត្តពាក់ព័ន្ធនឹងវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា។ ទន្ទឹមនោះដែររចនាសម្ព័ន្ធ និងមុខងាររបស់សាខាក៏ត្រូវបានពង្រឹង អនុលោមតាមគោលនយោបាយដែលផ្អែកលើគោលការណ៍អភិវឌ្ឍន៍ប្រតិបត្តិការធនាគារ ដើម្បីរួមចំណែកអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងតម្រូវការសេវាធនាគារកណ្តាលនៅទូទាំងប្រទេស ។ ជាមួយគ្នានេះដែរ ការលើកកម្ពស់ចំណេះដឹង និង ជំនាញវិជ្ជាជីវៈ មន្ត្រី-បុគ្គលិកទាំងនៅទីស្នាក់ការកណ្តាល ទាំងនៅសាខានានា ក៏ត្រូវបានយកចិត្តទុកដាក់ ជាពិសេសតាម រយៈការ បណ្តុះ បណ្តាល តាមគ្រប់រូបភាពជាប្រចាំ ។

ក្នុងនាមជាទេសាភិបាលធនាគារជាតិនៃកម្ពុជា ខ្ញុំសូមបញ្ជាក់ជាថ្មីម្តងទៀតនូវបំណង និងការប្តេជ្ញាដ៏ខ្ពស់របស់ ធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តយ៉ាងសកម្ម ជាដៃគូជាមួយវិស័យឯកជន បណ្តាក្រសួងពាក់ព័ន្ធ និងសហគមន៍អន្តរជាតិ ទាំងឡាយ ដើម្បីឈានទៅមុខជាលំដាប់ ជាមួយនឹងរបៀបវារៈកំណែទម្រង់នានាដែលបានកំណត់ សំដៅសម្រេចបាននូវ វិស័យធនាគារនិងហិរញ្ញវត្ថុមួយប្រកបដោយចីរភាព ថាមភាព និងតាមរយៈនេះ រួមចំណែកនាំមកនូវវឌ្ឍនភាពចំពោះ ប្រជាជនកម្ពុជា ។

នៅទីបញ្ចប់ ខ្ញុំសូមឆ្លៀតឱកាសនេះសម្តែងការអរគុណចំពោះក្រុមប្រឹក្សាភិបាល មន្ត្រីបុគ្គលិកធនាគារជាតិនៃ កម្ពុជា ចំពោះការលះបង់ស្វិតស្វាញ និងឧស្សាហ៍ព្យាយាមក្នុងការងារ ។ ប្រសិនបើគ្មានការចូលរួមទាំងនោះទេ សមិទ្ធផលទាំងឡាយដែលបានលើកឡើងលំអិតនៅក្នុងរបាយការណ៍នេះ នឹងពុំអាចកើតមានឡើងបានឡើយ ។ ខ្ញុំសង្ឃឹមជឿជាក់យ៉ាងមាំថា មន្ត្រី-បុគ្គលិកទាំងអស់នឹងបន្តដើរតួនាទីយ៉ាងសកម្មថែមទៀត ដើម្បីធានាបំពេញឱ្យបានយ៉ាងល្អនូវ មុខងារ-ភារកិច្ច ទាំងឡាយរបស់ធនាគារជាតិនៃកម្ពុជា ។

**ទេសាភិបាល**

# មាតិកា


ទំព័រ

ក. របាយការណ៍ប្រចាំឆ្នាំ ២០០៦ ១

សេចក្តីផ្តើម ២

I. ការវិវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា ៣

១. ស្ថានភាពតម្លៃប្រាក់រៀល ៣

១.១. ការវិវត្តសន្ទស្សន៍ថ្លៃទំនិញ និងសេវា (CPI) ៣

១.២. ស្ថានភាពអត្រាប្តូរប្រាក់ ៤

១.២.១. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ៤

១.២.២. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗ ៥

២. ការវិវត្តរូបិយវត្ថុ ៦

២.១. ការផ្គត់ផ្គង់រូបិយវត្ថុ ៦

២.២. កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ ៧

២.២.១. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា ៨

២.២.២. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារពាណិជ្ជ ៨

៣. ជញ្ជីងទូទាត់ ៩

៣.១. គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) ៩

៤. ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ១២

៤.១. ការវិនិយោគទុនបម្រុងអន្តរជាតិ ១២

៤.៣. ការគ្រប់គ្រងអាជីវកម្មមាស និងប្តូរប្រាក់ ១៣

៥. សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ១៣

៥.១. ការត្រួតពិនិត្យធនាគារពាណិជ្ជ ១៣

៥.១.១. ការត្រួតពិនិត្យលើឯកសារ ១៤

៥.១.២. ការត្រួតពិនិត្យដល់ទីកន្លែង ១៤

៥.២. ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ១៥

៥.៣. ការជម្រះបញ្ជីធនាគារដែលបានបិទទ្វារ ១៦

៥.៤. ការងាររៀបចំបទបញ្ញា ១៦

៦. ការផ្គត់ផ្គង់សេវាធនាគារកណ្តាល ១៧

៦.១. សេវាផ្នែកគណនី ១៧

៦.១.១. សេវាផ្ដែកគណនីចំពោះស្ថាប័នរដ្ឋ ១៧
៦.១.២. ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីរដ្ឋាភិបាល ១៧
៦.១.៣. សេវាផ្ដែកគណនីចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ១៨
៦.២. សេវាផាត់ទាត់ ១៨
៦.២.១. ការផាត់ទាត់មូលប្បទានប័ត្រចរឹកជាប្រាក់រៀល ១៨
៦.២.២. ការផាត់ទាត់មូលប្បទានប័ត្រចរឹកជាប្រាក់ដុល្លារអាមេរិក ១៨
៦.៣. ការងារឥណទាន ១៩
៧. ការគ្រប់គ្រងចរាចរណ៍ធនប័ត្រ ១៩
៨. ការងារគ្រប់គ្រងមូលប័ត្រ ២០
II. ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា ២០
១. សកម្មភាពក្រុមប្រឹក្សាភិបាល ២០
២. ការអភិវឌ្ឍធនធានមនុស្ស ២១
២.១. ស្ថិតិមន្ត្រី-បុគ្គលិក ២១
២.២. ការងារបណ្តុះបណ្តាល ២២
៣. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ២៣
៤. ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា ២៤
៥. ការងារគណនេយ្យធនាគារជាតិនៃកម្ពុជា ២៤
III. ទំនាក់ទំនងអន្តរជាតិ ២៦
១. ទំនាក់ទំនងពហុភាគី ២៦
១.២. ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ២៦
១.៤. ទំនាក់ទំនងជាមួយ SEACEN ២៨
១.៥. ទំនាក់ទំនងជាមួយក្រុមអាស៊ីប៉ាស៊ីហ្វិក (APG) ២៨
១.៦. ទំនាក់ទំនងជាមួយសមាគមឥណទានកសិកម្ម និងឥណទានជនបទតំបន់អាស៊ីប៉ាស៊ីហ្វិក (APRACA) ២៩
២. ទំនាក់ទំនងទ្វេភាគី ២៩
សន្និដ្ឋាន ៣០
ខ. ទិសដៅការងារឆ្នាំ ២០០៧ ៣២
ទិសដៅការងារឆ្នាំ ២០០៧ ៣៣
១. ការងាររូបិយវត្ថុ ៣៣

២. ការងារប្តូរប្រាក់ ៣៣

៣. ការងារត្រួតពិនិត្យ ៣៣

៤. ការងារគណនេយ្យ ៣៤

៥. ការងារប្រតិបត្តិការ ៣៤

៦. ការងារបោះផ្សាយ និងឃ្លាំងបេឡា ៣៤

៧. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ៣៤

៨. ការបណ្តុះបណ្តាល ៣៥

**ឧបសម្ព័ន្ធ ៣៦**

ឧបសម្ព័ន្ធ ១ : ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញ និងសេវា ៣៧

ឧបសម្ព័ន្ធ ២ : សន្ទស្សន៍ថ្លៃទំនិញ និងសេវា ឆ្នាំ ២០០២-២០០៦ ៣៨

ឧបសម្ព័ន្ធ ៣ : ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ ៣៩

ឧបសម្ព័ន្ធ ៤ : ស្ថានភាពរូបិយវត្ថុ (គិតជាពាន់លានរៀល) ៤០

ឧបសម្ព័ន្ធ ៥ : ស្ថានភាពរូបិយវត្ថុ (បម្រែបម្រួលប្រចាំខែជាភាគរយ) ៤១

ឧបសម្ព័ន្ធ ៦ : តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា ៤២

ឧបសម្ព័ន្ធ ៧ : តារាងគណនីវិភាគធនាគារពាណិជ្ជ ៤៣

ឧបសម្ព័ន្ធ ៨ : ឥណទានចំណាត់ថ្នាក់តាមមុខរបរ និងសរុបប្រតិបត្តិការប្រាក់បញ្ញើធនាគារពាណិជ្ជ ៤៤

ឧបសម្ព័ន្ធ ៩ : ជញ្ជីងទូទាត់ប្រទេសកម្ពុជា ឆ្នាំ ២០០៣ — ឆ្នាំ ២០០៦ ៤៥

# ក. របាយការណ៍ប្រចាំឆ្នាំ២០០៦

## សេចក្តីផ្តើម

ជាមួយនឹងការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ប្រុងប្រយ័ត្នរបស់រាជរដ្ឋាភិបាល ព្រមទាំងកំណែទម្រង់ចាំបាច់នៅលើវិស័យផ្សេងៗ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានៅតែរក្សាបាននូវកំណើនគួរឱ្យកត់សម្គាល់ ទោះបីជាជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនក្តី ។ តាមការព្យាករឆ្នាំ២០០៦នេះ កំណើនសេដ្ឋកិច្ចត្រូវបានរំពឹងថា នឹងមានកម្រិត ៩,៥% ធៀបនឹង ១៣,៤% នាឆ្នាំ២០០៥ ពោលគឺមានកំណើនទាបជាងឆ្នាំ២០០៥ ដែលជាឆ្នាំមានកំណើនដ៏លើសលប់ហួសពីការរំពឹងទុក ។

ក្នុងឆ្នាំ២០០៦ ទោះបីថ្លៃប្រេងបានបន្តកើនឡើងក៏ដោយ ក៏អត្រាអតិផរណាថ្លៃទំនិញប្រើប្រាស់មានកំណើនក្នុងកម្រិតបង្គួរមួយ គឺត្រឹម ២,៨% ប៉ុណ្ណោះ ធៀបទៅនឹង ៦,៧% នាឆ្នាំ២០០៥ ។ គោលនយោបាយរូបិយវត្ថុ និងសារពើពន្ធដ៏ត្រឹមត្រូវ បានបង្កលក្ខណៈឱ្យអត្រាប្តូរប្រាក់មានស្ថិរភាពយ៉ាងសមរម្យជាទូទៅក្នុងឆ្នាំ២០០៦ ហើយតម្លៃប្រាក់រៀលក៏កាន់តែប្រសើរឡើងផងដែរនាដំណាច់ឆ្នាំ ។

គួបផ្សំជាមួយអំណោយផលផ្នែកស្ថានភាពនយោបាយដែលកាន់តែវិវឌ្ឍប្រសើរឡើង និងកំណើនសេដ្ឋកិច្ចគួរជាទីពេញចិត្ត ប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាក៏ត្រូវបានពង្រីកនិងពង្រឹង ដោយទាក់ទាញបាននូវជំនឿទុកចិត្តកាន់តែច្រើនឡើងពីសាធារណជនក្នុងប្រទេស និងអន្តរជាតិ ។ ទន្ទឹមនឹងការលូតលាស់របស់វិស័យធនាគារ មីក្រូហិរញ្ញវត្ថុក៏ជាវិស័យមួយដែលកំពុងទទួលបានការចាប់អារម្មណ៍ដ៏ខ្លាំងក្លាពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ហើយក៏ជាការងារអាទិភាពមួយរបស់ធនាគារជាតិនៃកម្ពុជាដែរ ។ ការផ្តួចផ្តើមគំនិតរៀបចំសន្និសីទនានា និងការប្រកាសឆ្នាំ២០០៦ ជាឆ្នាំមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ជាព្រឹត្តិការណ៍ធ្វើឱ្យមីក្រូហិរញ្ញវត្ថុកម្ពុជាកាន់តែទទួលបានជោគជ័យថែមទៀត ដោយមានសកម្មភាពគ្របដណ្តប់កាន់តែទូលំទូលាយនៅទូទាំងប្រទេស ហើយប្រជាពលរដ្ឋកាន់តែច្រើនឡើងបានទទួលសេវាមីក្រូហិរញ្ញវត្ថុ ។

លើសពីនេះទៀត នៅក្នុងឆ្នាំ២០០៦ នេះ ធនាគារជាតិនៃកម្ពុជាបានចូលរួមចំណែករៀបចំកែលំអផែនការការងារថ្មី ដើម្បីកែទម្រង់រចនាសម្ព័ន្ធក្នុងវិស័យហិរញ្ញវត្ថុ និងធនាគារ ឱ្យសមស្របតាមកាលៈទេសៈ និងការប្រែប្រួលនៃបរិស្ថាន តាមរយៈការធ្វើបច្ចុប្បន្នកម្ម "ឯកសារចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០" ទៅជា "យុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥" ដើម្បីធ្វើឱ្យប្រព័ន្ធហិរញ្ញវត្ថុកាន់តែមានប្រសិទ្ធភាពរឹងមាំ និងស្ថិរភាពប្រកបដោយចីរភាព ។

# I. ការវិវត្តគោលនយោបាយរូបិយវត្ថុនិងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា

## ១. ស្ថានភាពតម្លៃប្រាក់រៀល

### ១.១. ការវិវត្តសន្ទស្សន៍ថ្លៃទំនិញ និងសេវា (CPI)

ក្នុងឆ្នាំ២០០៦ ការវិវត្តសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) បានបង្ហាញនិន្នាការកើនឡើងជាបន្តបន្ទាប់ ចាប់តាំងពីខែមេសាមក ប៉ុន្តែក្នុងសន្ទុះមួយដែលយឺតជាងឆ្នាំកន្លងទៅបន្តិច ។ បើប្រៀបធៀបទៅនឹងអំឡុងពេលចាប់ពីឆ្នាំ២០០៤ មក សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ក្នុងឆ្នាំនេះ មានការកើនឡើងតិចជាង ហើយការកើនឡើងនេះ ជាចម្បងបណ្តាលមកពីកំណើនថ្លៃប្រេង ម្ហូបអាហារ និងសម្លៀកបំពាក់ ។



ក្រាហ្វិកស្ថិតិ ១ : ការវិវត្តសន្ទស្សន៍ថ្លៃទំនិញនិងសេវា

សន្ទស្សន៍ថ្លៃទំនិញបានកើនឡើងពី ១១៨,១ ក្នុងខែធ្នូ ឆ្នាំ២០០៥ ដល់ ១២១,៥ ក្នុងខែធ្នូ ឆ្នាំ២០០៦ ដោយអត្រាអតិផរណាប្រចាំឆ្នាំស្មើនឹង ២,៨% ធៀបនឹងអត្រាអតិផរណា ៦,៧% ក្នុងឆ្នាំ២០០៥ និង ៥,៦% ក្នុងឆ្នាំ២០០៤ ដូច្នេះ គឺមានកម្រិតប្រសើរជាង កាលពី ២ ឆ្នាំមុន ។ កម្រិតអតិផរណានៅឆ្នាំ២០០៦ នេះ ត្រូវបានឆ្លុះបញ្ចាំងក្នុងកំណើនសន្ទស្សន៍រងម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ចំនួន ២% សន្ទស្សន៍រងដឹកជញ្ជូននិងទូរគមនាគមន៍ចំនួន ៧,៤% សន្ទស្សន៍រងផ្ទះសម្បែងនិងការប្រើប្រាស់ ៣,១% សន្ទស្សន៍រងសម្លៀកបំពាក់ចំនួន ២,៦% រួមផ្សំនឹងកំណើនសន្ទស្សន៍រងដទៃទៀតដែលបានកើនឡើងក្នុងរង្វង់ ១,៤% ។ ថ្លៃប្រេងឥន្ធនៈគ្រប់ប្រភេទនៅលើទីផ្សារក្នុងស្រុកបានបន្តកើនឡើងក្នុងនោះ ថ្លៃប្រេងសាំងមានកំណើនប្រហែល ៨,១% ប្រេងម៉ាស៊ូត ១២,៣% និងប្រេងម៉ាស៊ីន ១៤,៨% ។ ទន្ទឹមនោះ ទំនិញដែលជាគ្រឿងឧបភោគ-បរិភោគសំខាន់ៗ ដូចជា ត្រីបានឡើងថ្លៃ ៣,២% សាច់ ៣,២% និងបន្លែ ៩,៣% ។ ការណ៍នេះឆ្លុះបញ្ចាំងនូវកំណើននៃការផ្គត់ផ្គង់ត្រី សាច់ និងបន្លែ បានប្រសើរជាងឆ្នាំកន្លងទៅ ។




## ១.២. ស្ថានភាពអត្រាប្តូរប្រាក់

### ១.២.១. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក

នៅក្នុងឆ្នាំ២០០៦ នេះ ជាទូទៅអត្រាប្តូរប្រាក់រៀលរក្សាបាននូវលំនឹងមួយដ៏ប្រសើរ និងថែមទាំងមាននិន្នាការឡើងថ្លៃជាបន្តរទៀតផងក្នុងអំឡុងពេលឆ្ពោះទៅដំណាច់ឆ្នាំ ។ ប្រាក់រៀលមានតម្លៃមធ្យម ៤.០៩២រៀល ក្នុង ១ ដុល្លារអាមេរិក នាត្រីមាសទី១ ឆ្នាំ២០០៦ ។ នេះគឺជាការចុះថ្លៃ ១% ធៀបនឹងត្រីមាសទី ១ នៃឆ្នាំកន្លងទៅ តែជាការឡើងថ្លៃចំនួន ២% ធៀបនឹងត្រីមាសទី ៤ ឆ្នាំ២០០៥ ។ ប៉ុន្តែ ចាប់តាំងពីដើមត្រីមាសទី ២ រហូតដល់ចុងត្រីមាសទី ៣ ប្រាក់រៀលបានចុះថ្លៃជាបន្តបន្ទាប់ចំនួន ២,២% ពោលគឺពី ៤.០៩៧រៀល ក្នុង ១ ដុល្លារអាមេរិក នៅដំណាច់ខែមីនា ទៅ ៤.១៨៨ រៀល នៅដំណាច់ខែកញ្ញា ។ ការចុះថ្លៃនៃតម្លៃប្រាក់រៀលនេះ ជាទូទៅបណ្តាលមកពីកត្តារដូវកាល ភាពស្ងប់ស្ងាត់នៃតម្រូវការប្រាក់រៀលជាទ្រង់ទ្រាយធំ បញ្ហាទឹកជំនន់តាមដងផ្លូវជាតិមួយចំនួនដែលបង្កការរាំងស្ទះដល់ចលនាដឹកជញ្ជូនទំនិញ ។

នៅត្រីមាសទី៤ ឆ្នាំ២០០៦ តម្រូវការសាច់ប្រាក់រៀលសម្រាប់ការប្រមូលទិញកសិផល និងតម្រូវការបង់ពន្ធអាករផ្សេងៗនាដំណាច់ឆ្នាំ ធ្វើឱ្យប្រាក់រៀលមានភាពប្រសើរនៅអំឡុងពេលចុងឆ្នាំ ។ នៅខែធ្នូ អត្រាទិញទីផ្សារបានធ្លាក់ចុះបន្តបន្ទាប់ដល់ ៤.០៥៨រៀល ក្នុង ១ ដុល្លារអាមេរិក ។ ជាទូទៅ គួរកត់សម្គាល់ថា អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ក្នុងឆ្នាំ២០០៦ នេះ មាននិន្នាការប្រសើរជាងឆ្នាំ២០០៥ ដោយអត្រាមធ្យមប្រចាំឆ្នាំ២០០៦ មានកម្រិត ៤.១១៨រៀល ក្នុង ១ ដុល្លារអាមេរិក ធៀបនឹងអត្រាមធ្យមប្រចាំឆ្នាំ២០០៥ ចំនួន ៤.១២៤រៀល ក្នុង ១ ដុល្លារអាមេរិក ។

## តារាងអត្រាប្តូរប្រាក់រៀល ធៀបនឹងប្រាក់ដុល្លារអាមេរិក

(រៀលក្នុងមួយដុល្លារអាមេរិក)

| | អត្រាប្តូរប្រាក់ប្រចាំខែ ( ចុងខែ) | | | | | |
|---|---|---|---|---|---|---|
| | អត្រាទីផ្សារ | | | អត្រាផ្លូវការ | | |
| | ទិញ | លក់ | មធ្យម | ទិញ | លក់ | មធ្យម |
| ធ្នូ-០៥ | ៤.១១៧ | ៤.១២៣ | ៤.១២០ | ៤.១១២ | ៤.១២០ | ៤.១១៦ |
| មករា-០៦ | ៤.០៩២ | ៤.១១៣ | ៤.១០៣ | ៤.០៧៧ | ៤.០៨៥ | ៤.០៨១ |
| កុម្ភៈ-០៦ | ៤.០៨៨ | ៤.០៩៩ | ៤.០៩៤ | ៤.០៧៩ | ៤.០៨៧ | ៤.០៨៣ |
| មីនា-០៦ | ៤.០៩៧ | ៤.១០៨ | ៤.១០៣ | ៤.០៩៥ | ៤.១០៣ | ៤.០៩៩ |
| មេសា-០៦ | ៤.១០៥ | ៤.១១៥ | ៤.១១០ | ៤.០៩២ | ៤.១០០ | ៤.០៩៦ |
| ឧសភា-០៦ | ៤.១១៣ | ៤.១២១ | ៤.១១៧ | ៤.១០២ | ៤.១១០ | ៤.១០៦ |
| មិថុនា-០៦ | ៤.១១៨ | ៤.១២៦ | ៤.១២២ | ៤.១១០ | ៤.១១៨ | ៤.១១៤ |
| កក្កដា-០៦ | ៤.១៣៣ | ៤.១៤១ | ៤.១៣៧ | ៤.១១៤ | ៤.១២២ | ៤.១១៨ |
| សីហា-០៦ | ៤.១៧០ | ៤.១៨០ | ៤.១៧៥ | ៤.១៤៤ | ៤.១៥២ | ៤.១៤៨ |
| កញ្ញា-០៦ | ៤.១៨៨ | ៤.១៩៥ | ៤.១៩២ | ៤.១៥៤ | ៤.១៦២ | ៤.១៥៨ |
| តុលា-០៦ | ៤.១៥៣ | ៤.១៦៥ | ៤.១៥៩ | ៤.១៥០ | ៤.១៥៨ | ៤.១៥៤ |
| វិច្ឆិកា-០៦ | ៤.១០៣ | ៤.១១៣ | ៤.១០៨ | ៤.០៩៩ | ៤.១០៧ | ៤.១០៣ |
| ធ្នូ-០៦ | ៤.០៥៨ | ៤.០៧២ | ៤.០៦៥ | ៤.០៥៧ | ៤.០៦៥ | ៤.០៦១ |

### ១.២.២. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗ

ចលនានៃអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗ តាមការគណនាខ្វែងគ្នាបានបង្ហាញថា ក្នុងឆ្នាំ ២០០៦ នេះ ប្រាក់រៀលមានភាពទន់ខ្សោយជាបន្តរធៀបនឹងរូបិយវត្ថុបណ្តាប្រទេសមួយចំនួន ជាពិសេស រូបិយប័ណ្ណនៃប្រទេសអាស៊ាន និងដៃគូពាណិជ្ជកម្មខ្លះទៀតក្រៅពីសហរដ្ឋអាមេរិក ។ នាឆ្នាំនេះ ប្រាក់រៀលបានចុះថ្លៃ ៩.៤% ធៀបនឹងប្រាក់អឺរ៉ូ ដោយឡែក នៅឆ្នាំ២០០៥ ប្រាក់រៀលឡើងថ្លៃ ១១.២% ធៀបនឹងប្រាក់អឺរ៉ូ ។ ប្រាក់រៀលបានឡើងថ្លៃធៀបនឹងប្រាក់ដុងវៀតណាម ២.៣% យ៉េនជប៉ុន ២.២% និងដុល្លារហុងកុង ១.៥% តែបានចុះថ្លៃធៀបនឹងប្រាក់បាតថៃ ១២% រីងហ្គីតម៉ាឡេស៊ី ៥.៤% វ៉ុនកូរ៉េ ៧.៤% និងដុល្លារសិង្ហបុរី ៦.៦% ។

**ក្រាហ្វិកទី ៣ ៖ ការវិវត្តនៃតម្លៃប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន**




* ខ្សែគំនូសឡើងលើបង្ហាញអំពីការចុះថ្លៃនៃប្រាក់រៀល

## ២. ការវិវត្តរូបិយវត្ថុ

រូបិយវត្ថុទូទៅ (M2) និងទ្រព្យសកម្មបរទេសសុទ្ធរបស់ប្រព័ន្ធធនាគារក្នុងអំឡុងឆ្នាំ២០០៦ នេះ បានបន្តកើនឡើងក្នុងអត្រាកំណើនច្រើនជាងទ្វេដងធៀបនឹងឆ្នាំមុន ខណៈដែលទ្រព្យសកម្មក្នុងស្រុកសុទ្ធក៏បានកើនឡើងជាបង្គួរផងដែរ ។ គួរបញ្ជាក់ផងដែរថា ឥណទានចំពោះវិស័យឯកជនមានការកើនឡើងខ្ពស់ធៀបនឹងកំណើនកាលពីឆ្នាំមុន ខណៈដែលអតិផរណា និងអត្រាប្តូរប្រាក់រៀលពុំមានការប្រែប្រួលខ្លាំង ដែលឆ្លុះបញ្ចាំងនូវកំណើនតម្រូវការប្រាក់រៀលក្នុងសេដ្ឋកិច្ច ។ ប៉ុន្តែ កំណើននេះពុំមានឥទ្ធិពលប៉ុន្មានទៅលើកំណើនទ្រព្យសកម្មក្នុងស្រុកសុទ្ធឡើយ ដោយសារតែមានការទូទាត់ប៉ះប៉ូវមកវិញដោយកំណើនយ៉ាងខ្លាំងនៃប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលនៅនឹងវិស័យធនាគារ ជាពិសេស គឺមូលនិធិដែលបានមកពីការលុបបំណុលរបស់មូលនិធិរូបិយវត្ថុអន្តរជាតិកាលពីដើមឆ្នាំនេះ រួមទាំងការកើនឡើងនៃដើមទុនរបស់ប្រព័ន្ធធនាគារនៅកម្ពុជាផងដែរ ។ ជាមួយគ្នានេះ អត្រាកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណ និងទ្រព្យសកម្មបរទេសរបស់ធនាគារជាតិនៃកម្ពុជា ក៏បង្ហាញនូវកម្រិតមួយខ្ពស់ជាងឆ្នាំ២០០៥ ដែរ ។ (សូមអានតារាងនៅទំព័រទី៧)

### ២.១. ការផ្គត់ផ្គង់រូបិយវត្ថុ

ក្នុងឆ្នាំ២០០៦នេះ រូបិយវត្ថុទូទៅ (M2) បានកើនឡើងចំនួន១.៩១៧,៣ពាន់លានរៀល (៣៨,២%) ពោលគឺកើនពី ៥.០២៤,៩ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០០៥ ទៅ ៦.៩៤២,៣ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០០៦ ។ ការកើនឡើងនៃរូបិយវត្ថុទូទៅ ជាចម្បងបណ្តាលមកពីកំណើននៃប្រាក់បញ្ញើជារូបិយប័ណ្ណរបស់និវាសជនចំនួន ១.៦០៦,៦ពាន់លានរៀល (៤៤,៨%) គួបផ្សំជាមួយនឹងការកើនឡើងនៃរូបិយវត្ថុក្នុងចរាចរណ៍ចំនួន ៣១៧,៤ពាន់លានរៀល (២៤,៨%) ។ គួរកត់សម្គាល់ថា ប្រាក់បញ្ញើជារូបិយប័ណ្ណមានសន្ទុះកើនយ៉ាងលឿនជាងឆ្នាំមុនៗទាំងអស់ ក្នុងរយៈពេល ១២ឆ្នាំកន្លងមកនេះ ។ ផ្អែកលើទិន្នន័យប្រចាំខែ ប្រាក់បញ្ញើជារូបិយប័ណ្ណបានបន្តកើនឡើងរហូត ចាប់តាំងពីខែមករារហូត

ដល់ខែធ្នូ ឆ្នាំ២០០៦ ។ ដូច្នេះ ការវិវត្តរូបិយវត្ថុក្នុងឆ្នាំ២០០៦ នេះ បានឆ្លុះបញ្ចាំងឱ្យឃើញពីកំណើនយ៉ាងខ្ពស់គួរឱ្យកត់សម្គាល់នៃការប្រើប្រាស់សេវាធនាគារ បន្ទាប់ពីមានធនាគារចំណូលថ្មី ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់របស់ធនាគារពាណិជ្ជធំៗមួយចំនួន និងការជំរុញឱ្យប្រើប្រាស់សេវាធនាគារដោយរាជរដ្ឋាភិបាល ក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមក ។

**តារាងបម្រែបម្រួលជាភាគរយនៃស្ថិតិរូបិយវត្ថុសំខាន់ៗ និងសន្ទស្សន៍ថ្លៃទំនិញនិងសេវា**

| | **២០០២** | **២០០៣** | **២០០៤** | **២០០៥** | **ធ្នូ.០៦** |
|---|---|---|---|---|---|
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | -៥៨,៨% | -៧,៤% | -៦៣,១% | -១០១,៨% | -១២៦,៤% |
| ឥណទានចំពោះផ្នែកឯកជន | ១៣,១% | ២៦,២% | ៣៥,៩% | ៣១,៨% | ៥១,៦% |
| រូបិយវត្ថុទូទៅ (M2) | ៣១,១% | ១៥,៣% | ៣០,០% | ១៦,១% | ៣៨,២% |
| រូបិយវត្ថុក្នុងចរាចរណ៍ | ៣២,៦% | ១៨,៦% | ២២,៧% | ១៥% | ២៤,៨% |
| អតិផរណាប្រចាំឆ្នាំ | ៣,៨% | ០,៥% | ៥,៦% | ៦,៧% | ២,៨% |

## ២.២. កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ

ក្នុងឆ្នាំ២០០៦ រូបិយវត្ថុទូទៅ (M2) មានកំណើនច្រើនជាងឆ្នាំមុន គឺដោយសារការកើនឡើងយ៉ាងខ្ពស់នៃទ្រព្យសកម្មបរទេសសុទ្ធរបស់ប្រព័ន្ធធនាគារ និងការកើនឡើងជាបង្គួរនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ ។ ទ្រព្យសកម្មបរទេសសុទ្ធបានកើនឡើងចំនួន ១.៧៤៩,២ពាន់លានរៀល (៣១,៩%) និងទ្រព្យសកម្មក្នុងស្រុកសុទ្ធបានកើនចំនួន ១៦៨,២ពាន់លានរៀល (៣៧,៤%) ។ ការកើនឡើងនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ គឺបណ្តាលមកពីកំណើនយ៉ាងខ្ពស់គួរឱ្យកត់សម្គាល់នៃខ្ទង់ឥណទានចំពោះវិស័យឯកជនចំនួន ១.២៣៤,១ពាន់លានរៀល (៥១,៦%) ដែលជាអត្រាកំណើនខ្ពស់ជាងគេក្នុងរយៈពេលដប់ពីរឆ្នាំកន្លងមក និងខ្ទង់ផ្សេងៗបានកើនឡើងចំនួន ៩៧,១ពាន់លានរៀល (២៨,៥%) ។ ប៉ុន្តែកំណើននេះត្រូវបានផាត់ទាត់មកវិញដោយការថយចុះយ៉ាងខ្លាំងនៃឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលចំនួន ៥៣២,២ពាន់លានរៀល (១២៦,៤%) និងការកើនឡើងនៃដើមទុនរបស់ប្រព័ន្ធធនាគារចំនួន ៦០០,៩ពាន់លានរៀល (២២,៨%) ។ កំណើនសំខាន់ៗនៃឥណទានចំពោះវិស័យឯកជនមាន : ឥណទានចំពោះវិស័យសេវាកម្មកើនចំនួន ៣៣៤,៧ពាន់លានរៀល (៤១,៣%) វិស័យលក់ដុំនិងលក់រាយ ២៩៩ពាន់លានរៀល (៤៩,៤%) វិស័យកម្មន្តសាលកម្ម ១៤៣,៥ពាន់លានរៀល (៥៣,៧%) វិស័យអចលនវត្ថុនិងការប្រើប្រាស់សាធារណៈ ១៥០,៩ពាន់លានរៀល (១០១,៩%) វិស័យសំណង់ ១២៥ពាន់លានរៀល (៨៦,២%) និងវិស័យកសិកម្ម ៧៩,៣ពាន់លានរៀល (១១៤,៥%) ។

### ២.២.១. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា

ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជាបានថយចុះចំនួន ៥៤៩,៤ពាន់លានរៀល (៣០,៦%) ពោលគឺថយចុះពី -១.៧៩៦,៦ពាន់លានរៀលនៅខែធ្នូ ឆ្នាំ២០០៥ មក -២.៣៤៥,៩ពាន់លានរៀលក្នុងខែធ្នូ ឆ្នាំ២០០៦ នេះ បន្ទាប់ពីបានថយចុះចំនួន ៣៤៦,៨ពាន់លានរៀល (២៣,៩%) ក្នុងឆ្នាំកន្លងទៅ ។ ការថយចុះនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធជាចម្បងគឺបណ្តាលមកពីការថយចុះឥណទេយ្យសុទ្ធរាជរដ្ឋាភិបាលចំនួន ៤០០,២ពាន់លានរៀល (៩៨,៤%) គួបផ្សំជាមួយនឹងការកើនឡើងនៃដើមទុនរបស់ធនាគារជាតិនៃកម្ពុជាចំនួន ២៨៤,២ពាន់លានរៀល (១៨,៨%) ដែលជាលទ្ធផលនៃការវាយតម្លៃឡើងវិញនៃទ្រព្យសកម្ម ។ ការថយចុះឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល គឺបណ្តាលមកពីការកើនឡើងនៃប្រាក់បញ្ញើរាជរដ្ឋាភិបាលចំនួន ៤១៦,២ពាន់លានរៀល (៦១,៥%) ។ ក្នុងឆ្នាំនេះដែរ ឥណទេយ្យសុទ្ធចំពោះបណ្តាធនាគារទទួលប្រាក់បញ្ញើបានកើនឡើងចំនួន ៩,២ពាន់លានរៀល (៩,១%) ចំណែកខ្ទង់ផ្សេងៗសុទ្ធបានថយចុះចំនួន ១៥៨,១ពាន់លានរៀល (១២,២%) ។

ក្នុងអំឡុងឆ្នាំ២០០៦ នេះដែរ ទ្រព្យសកម្មបរទេសសុទ្ធបានកើនឡើងយ៉ាងខ្ពស់ចំនួន ១.២៩៥ពាន់លានរៀល (២៩,២%) ពោលគឺកើនពី ៤.៤៣៣,៧ពាន់លានរៀល ក្នុងឆ្នាំ២០០៥ ដល់ ៥.៧២៨,៧ពាន់លានរៀលក្នុងឆ្នាំ២០០៦ នេះ ។ កំណើននេះបណ្តាលមកពីការកើនឡើងនៃទ្រព្យសកម្មបរទេសចំនួន៩៦១ពាន់លានរៀល(២០,២%) និងការថយចុះទ្រព្យអកម្មបរទេសចំនួន ៣៣៤ពាន់លានរៀល (១០០%) ។ ការថយចុះនៃទ្រព្យអកម្មបរទេស (១០០%) នេះ គឺបណ្តាលមកពីការលុបបំណុលទាំងស្រុងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិចំពោះប្រទេសកម្ពុជា ។

### ២.២.២. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារពាណិជ្ជ

ក្នុងឆ្នាំ២០០៦ ទ្រព្យសកម្មសរុបរបស់បណ្តាធនាគារពាណិជ្ជបានកើនឡើងខ្លាំងចំនួន ២.៣៨៤ពាន់លានរៀល (៤២,៧%) ។ ក្នុងអំឡុងពេលនេះដែរ ទ្រព្យអកម្មក្នុងស្រុកក្នុងរូបភាពជាប្រាក់បញ្ញើបានកើនឡើងខ្លាំងផងដែរ ដែលជាកត្តាសំខាន់មួយគាំទ្រដល់សកម្មភាពឥណទានរបស់ធនាគារ ហើយនឹងរួមចំណែកដល់ការវិនិយោគនៅក្នុងសេដ្ឋកិច្ច ។

ទ្រព្យសកម្មក្នុងស្រុកសុទ្ធបានកើនឡើងចំនួន ៦៨៧,១ពាន់លានរៀល (៥៣,៩%) ក្នុងឆ្នាំ២០០៦ នេះ ។ កំណើននេះ ជាចម្បងបណ្តាលមកពីការកើនឡើងនៃឥណទានចំពោះផ្នែកឯកជនចំនួន ១.២៣៤,៤ពាន់លានរៀល (៥១,៦%) ខណៈដែលឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលបានថយចុះចំនួន ១៣២ពាន់លានរៀល (៩១៥%) និងខ្ទង់ផ្សេងៗសុទ្ធបានថយចុះចំនួន ៤១៧,២ពាន់លានរៀល (៣៧,៦%) ។ ការថយចុះខ្ទង់ផ្សេងៗសុទ្ធឆ្លុះបញ្ចាំងនូវការកើនឡើងនៃដើមទុនធនាគារពាណិជ្ជមួយចំនួន និងដើមទុនរបស់ធនាគារឯកទេសដែលទើបបើកថ្មីចំនួន ២ ពោលគឺកើនចំនួន ៣១៦,៧ពាន់លានរៀល (២៨%) ព្រមទាំងការកើនឡើងនៃទ្រព្យអកម្មផ្សេងៗចំនួន ៣០១,៤ពាន់លានរៀល (១០១,៩%) និងការកើនឡើងនៃប្រាក់បញ្ញើធានាដើមទុន (Restricted Deposit) ចំនួន ៨,២ពាន់លានរៀល (៧៣,៤%) ។ ចំណែកឯទ្រព្យសកម្មផ្សេងៗបានកើនចំនួន ២០៩,១ពាន់លានរៀល (៦៣,៦%) ។ ក្នុងអំឡុងពេលនេះដែរ ប្រាក់បញ្ញើរបស់

បណ្តាធនាគារពាណិជ្ជនៅធនាគារជាតិនៃកម្ពុជាដែលជាធាតុផ្សំនៃទុនបម្រុងអន្តរជាតិ បានកើនឡើងចំនួន ៤៤៤,៧ពាន់លានរៀល (៣១,៩%) ។

ទ្រព្យសកម្មបរទេសសុទ្ធរបស់បណ្តាធនាគារពាណិជ្ជបានកើនឡើងចំនួន ៤៥៤,២ពាន់លានរៀល (៤៣,៦%) គឺកើនពី ១.០៤១,៤ពាន់លានរៀលនៅខែធ្នូ ឆ្នាំ២០០៥ ដល់ ១.៤៩៥,៦ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០០៦ ។ កំណើននេះបណ្តាលមកពីការកើនឡើងនៃទ្រព្យសកម្មបរទេសចំនួន ៥៤៦,៩ពាន់លានរៀល (៣៩,៨%) ខណៈដែលទ្រព្យអកម្មបរទេសកើនឡើងតែ ៩២,៧ពាន់លានរៀល (២៧,៨%) ប៉ុណ្ណោះ ។

ទ្រព្យអកម្មក្នុងស្រុកជាប្រភេទប្រាក់បញ្ញើបានកើនចំនួន ១.៥៨៨,៩ពាន់លានរៀល (៤២,៥%) ក្នុងនោះប្រាក់បញ្ញើជារូបិយប័ណ្ណរបស់និវាសជន ដែលជាធាតុផ្សំចម្បងនៃទ្រព្យអកម្មក្នុងស្រុកបានកើនឡើងយ៉ាងខ្លាំងចំនួន ១.៦០៦,៦ពាន់លានរៀល (៤៤,៨%) និងប្រាក់បញ្ញើចរន្តជារៀលបានកើនឡើងចំនួន ៦,៤ពាន់លានរៀល (១៨,៦%) ខណៈដែលប្រាក់បញ្ញើមានកាលកំណត់និងសន្សំជារៀលបានថយចុះចំនួន ២៤,១ពាន់លានរៀល (២១,៤%) ។

## ៣- ជញ្ជីងទូទាត់

តាមទិន្នន័យប៉ាន់ស្មានដំបូងសម្រាប់ឆ្នាំ២០០៦ នេះ ប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាបានបង្ហាញថា សមតុល្យរួមមានអតិរេកចំនួន ១៧៥,៦លានដុល្លារអាមេរិក គឺបានកើនឡើង ១០១,៥លានដុល្លារអាមេរិក បើធៀបនឹងឆ្នាំ២០០៥ ។ ការកើនឡើងនេះជាចម្បងបណ្តាលមកពីការថយចុះនៃឱនភាពគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) ប្រមាណ ២,៧% ធៀបនឹងឆ្នាំកន្លងទៅ ខណៈដែលគណនីដើមទុននិងហិរញ្ញវត្ថុសម្រាប់ផាត់ទាត់ឱ្យឱនភាពនេះមានកំណើន ១៥,៤% ។ ក្នុងឆ្នាំ២០០៦ នេះ ផលធៀបនៃឱនភាពគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) និងផលិតផលក្នុងស្រុកសរុបមានកម្រិត ៨,៥% ។

### ៣.១- គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ)

ក្នុងឆ្នាំ២០០៦ នេះ គណនីចរន្តត្រូវបានប៉ាន់ស្មានថា មានឱនភាពចំនួន ៥៧៥,៥លានដុល្លារអាមេរិក គឺបានថយចុះ ១៥,៨លានដុល្លារអាមេរិក (២,៧%) ធៀបនឹងឆ្នាំ២០០៥ ។ ការកើនឡើងនៃអតិរេកគណនីសេវាសុទ្ធ និងគណនីបង្វែរឯកជនសុទ្ធ ជាមូលហេតុសំខាន់នៃការថយចុះឱនភាពគណនីចរន្ត ខណៈដែលឱនភាពជញ្ជីងពាណិជ្ជកម្ម និងគណនីប្រាក់ចំណូលសុទ្ធបានកើនឡើងប្រមាណ ១២% ដូចគ្នា ។

ចំពោះការនាំចេញផលិតផលក្នុងស្រុកនៅក្នុងឆ្នាំ២០០៦ នេះវិញ ត្រូវបានប៉ាន់ស្មានថា មានចំនួន ៣.៤៥០,១លានដុល្លារអាមេរិក គឺបានកើនឡើង ៦៧៧,៣លានដុល្លារអាមេរិក (២៤,៤%) ធៀបនឹងឆ្នាំ២០០៥ ។ កត្តារួមចំណែកយ៉ាងសំខាន់នៅក្នុងកំណើននេះ គឺការកើនឡើងនូវការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌចំនួន ៤២៥,៤លានដុល្លារអាមេរិក (១៨,៨%) ។ លទ្ធផលល្អប្រសើរនៃការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌក្នុងឆ្នាំនេះអាស្រ័យដោយមូលហេតុចម្បង២ពីរគឺ : (១) ការដាក់កំហិតដល់ការនាំចូលផលិតផលវាយនភ័ណ្ឌរបស់ប្រទេសចិនទៅ

កាន់សហរដ្ឋអាមេរិកនិងសហគមន៍អឺរ៉ុប នៅក្រោមវិធានការសុវត្ថិភាពនៃអង្គការពាណិជ្ជកម្មពិភពលោក និង (២) ផលិតផលវាយនភ័ណ្ឌរបស់ប្រទេសកម្ពុជា នៅមានតម្លៃទាបដែលអាចមានលទ្ធភាពប្រកួតប្រជែងជាមួយប្រទេសកំពុងអភិវឌ្ឍមួយចំនួន ។ ក្នុងឆ្នាំនេះ ការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌមានសមាមាត្រ ៧០,២% នៃការនាំចេញផលិតផលក្នុងស្រុក ។ ក្នុងអំឡុងពេលដដែលនេះ ការនាំចេញផលិតផលក្នុងស្រុកផ្សេងទៀតបានកើនឡើង ២៥១,៩ លានដុល្លារអាមេរិក (៤៩,២%) ក្នុងនោះរួមមានការកើនឡើងនូវការនាំចេញផលិតផលស្រូវ ត្រី កៅស៊ូ គ្រឿងសង្ហារិម និងផលិតផលកសិកម្មផ្សេងៗទៀត ។

ដោយឡែក តម្លៃនាំចូលទំនិញសម្រាប់ប្រើប្រាស់ក្នុងស្រុកត្រូវបានប៉ាន់ស្មានថា មានចំនួន ៤.៦១៦,៤លានដុល្លារអាមេរិក គឺបានកើនឡើង ៨០៦,៦លានដុល្លារអាមេរិក (២១,២%) ធៀបនឹងឆ្នាំ២០០៥ ។ កត្តាចម្បងរួមចំណែកក្នុងការកើនឡើងនេះ គឺតម្លៃនាំចូលប្រេងឥន្ធនៈដែលបានកើនដល់ចំនួន ១.១៧៦,៥លានដុល្លារអាមេរិក ពោលគឺមានកំណើន ៣៣៤,៩លានដុល្លារអាមេរិក (៣៩,៨%) ។ បរិមាណនាំចូលត្រូវបានប៉ាន់ស្មានថា បានកើនឡើង ៩% ប៉ុណ្ណោះ ធៀបនឹងឆ្នាំ២០០៥ ។ គួរកត់សម្គាល់ថា តម្លៃនៃការនាំចូលប្រេងឥន្ធនៈមានសមាមាត្រ ២៥,៥% នៃការនាំចូលទំនិញប្រើប្រាស់ក្នុងស្រុកសរុប ។ ថ្លៃប្រេងនៅទីផ្សារអន្តរជាតិជាមធ្យមត្រូវបានប៉ាន់ស្មានថា មានកម្រិត ៦៩,២ដុល្លារក្នុង ១ បារ៉ែល មានកំណើន ២៩,៧% ធៀបនឹងឆ្នាំកន្លងទៅ ។ ចំណែកការនាំចូលទំនិញប្រើប្រាស់ក្នុងស្រុកផ្សេងទៀត ដូចជា ការនាំចូលវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់បានកើនឡើង ១៥,៩% ហើយការនាំចូលទំនិញផ្សេងៗ បានកើនឡើង ១៥,៩% ។




ក្នុងអំឡុងឆ្នាំនេះដែរ អតិរេកនៃគណនីសេវាសុទ្ធបានកើនឡើងដល់ ៥៧៨,៣លានដុល្លារអាមេរិក ពោលគឺបានកើនឡើង ១០៧,៣លានដុល្លារអាមេរិក (២២,៨%) ធៀបនឹងឆ្នាំ២០០៥ ។ ការកើនឡើងនៃអតិរេកនេះ ជាលទ្ធផលនៃកំណើនប្រាក់ចំណូលពីផ្នែកសេវាដែលមានទំហំច្រើនលើសកំណើននៃចំណាយទូទាត់សេវាទៅឱ្យអនិវាសជន ។ កត្តាសំខាន់

រួមចំណែកក្នុងកំណើនប្រាក់ចំណូលនេះ គឺចំណូលពីសេវាទេសចរណ៍និងសេវាដឹកជញ្ជូនដែលបានបង្ហាញថា ការកែទម្រង់សេវាសាធារណៈ ការអភិវឌ្ឍវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន ព្រមទាំងគោលនយោបាយទាក់ទាញទេសចររបស់រដ្ឋាភិបាលតាមរយៈការតាំងពិព័រណ៍ជាលក្ខណៈអន្តរជាតិផ្សេងៗ បានទទួលជោគជ័យយ៉ាងប្រសើរ ដោយបានធ្វើឱ្យចំនួនភ្ញៀវបរទេសដែលបានចូលមកទស្សនាប្រទេសកម្ពុជាក្នុងឆ្នាំ២០០៦ នេះ មានការកើនឡើងរហូតដល់ប្រមាណ ១,៧លាននាក់ ដែលចំនួននេះមានត្រឹមតែ ១,៣លាននាក់ ក្នុងឆ្នាំ២០០៥ ។ ចំពោះគណនីប្រាក់ចំណូលសុទ្ធត្រូវបានប៉ាន់ស្មានថា មានឱនភាពចំនួន ២៨៦,១លានដុល្លារអាមេរិក គឺមានកំណើន ៣២,១លានដុល្លារអាមេរិក (១២,៦%) ធៀបនឹងឆ្នាំ២០០៥ ។ ការកើនឡើងនៃឱនភាពនេះ គឺដោយសារកំណើននៃការផ្ទេរប្រាក់ចេញទៅឱ្យអនិវាសជនបានកើនលើសកំណើននៃប្រាក់ចំណូលដែលទទួលបានពីបរទេស ។ ចំណែកអតិរេកនៃគណនីបង្វែរឯកជនសុទ្ធបានកើន ៦២,២លានដុល្លារអាមេរិក (២៩,៧%) ក្នុងនោះ មួយផ្នែកធំគឺជាកំណើនប្រាក់បង្វែររបស់ជនជាតិកម្ពុជា ដែលធ្វើការនៅក្រៅប្រទេស ។

## ៣.២. គណនីដើមទុន និងហិរញ្ញវត្ថុ

ក្នុងឆ្នាំ២០០៦ នេះ សមតុល្យគណនីចរន្ត និងបង្វែរដើមទុន មានឱនភាពត្រឹម ១៣៥,៣លានដុល្លារអាមេរិក ធៀបនឹងឱនភាព ២៦៥,៦លានដុល្លារអាមេរិក នាឆ្នាំកន្លងទៅ ។ លំហូរបង្វែរផ្លូវការសុទ្ធត្រូវបានប៉ាន់ស្មានថា មានចំនួន ៤៤០,២លានដុល្លារអាមេរិក គឺមានកំណើន ១១៤,៥លានដុល្លារអាមេរិក ស្មើ ៣៥,២% ធៀបនឹងកម្រិតនាឆ្នាំ២០០៥ ។ គណនីនេះបង្ហាញពីលំហូរហិរញ្ញប្បទានសហប្រតិបត្តិការ ដែលរាជរដ្ឋាភិបាលកម្ពុជាទទួលបានពីសហគមន៍អន្តរជាតិទាំងពហុភាគីនិងទ្វេភាគី ក្នុងនោះរួមមាន ហិរញ្ញប្បទានសម្រាប់ទ្រទ្រង់ថវិកា ៣លានដុល្លារអាមេរិក ហិរញ្ញប្បទានសម្រាប់ស្បៀងអាហារ ២៥លានដុល្លារអាមេរិក ហិរញ្ញប្បទានសម្រាប់គម្រោង ២៥២,៦លានដុល្លារអាមេរិក និងហិរញ្ញប្បទានសម្រាប់ជំនួយបច្ចេកទេស ១៥៩,៨លានដុល្លារអាមេរិក ។ ទន្ទឹមនឹងនេះ លំហូរហិរញ្ញប្បទានជាប្រាក់កម្ចីផ្លូវការសុទ្ធ (មិនរាប់បញ្ចូលប្រាក់កម្ចីពីមូលនិធិរូបិយវត្ថុអន្តរជាតិ) ត្រូវបានប៉ាន់ស្មានថា មានចំនួន ១៦៨,៨លានដុល្លារអាមេរិក គឺបានកើនឡើង ១៧,២% ធៀបនឹងឆ្នាំ២០០៥ ។ ក្នុងឆ្នាំនេះ លំហូរវិនិយោគផ្ទាល់បរទេសសុទ្ធត្រូវបានប៉ាន់ស្មានថា មានចំនួន ៤០៣,៨លានដុល្លារអាមេរិក ក្នុងនោះ លំហូរវិនិយោគផ្ទាល់បរទេសផ្នែកសហគ្រាសមានចំនួន ៣៥០,១លានដុល្លារអាមេរិក ។ កំណើនលំហូរវិនិយោគផ្ទាល់បរទេសផ្នែកសហគ្រាសនេះឆ្លុះបញ្ចាំងនូវគម្រោងវិនិយោគចំនួន ៣៦ ដែលបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដូចជា គម្រោងវិនិយោគផ្នែកកាត់ដេរសម្លៀកបំពាក់និងទំនិញវាយនភ័ណ្ឌ ផ្នែកសណ្ឋាគារ និងផ្នែកអភិវឌ្ឍន៍ដីកសិកម្ម ។

ការកើនឡើងនៃគណនីដើមទុន និងហិរញ្ញវត្ថុ ដូចបានបង្ហាញពីខាងលើ មានលទ្ធភាពទ្រទ្រង់ និងផាត់ទាត់ចំពោះឱនភាពគណនីចរន្តបានទាំងស្រុង ។ ជាលទ្ធផលនៃប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០០៦ នេះ សមតុល្យរួមមានអតិរេក ១៧៥,៦លានដុល្លារអាមេរិក ។ គិតដល់ចុងឆ្នាំ២០០៦ ទុនបម្រុងអន្តរជាតិអាចធានាឱ្យការទូទាត់ទំនិញនាំចូលបាន ២,៩ ខែ ។




# ៤. ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

## ៤.១. ការវិនិយោគទុនបម្រុងអន្តរជាតិ

ទុនបម្រុងអន្តរជាតិដុលជារូបិយប័ណ្ណនៅបរទេសត្រូវបានធ្វើវិនិយោគដោយប្រុងប្រយ័ត្នជាមួយធនាគារកណ្តាលប្រទេសអភិវឌ្ឍ ធនាគារពាណិជ្ជបរទេសដែលមានចំណាត់ថ្នាក់ខ្ពស់ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ។ ទុនបម្រុងអន្តរជាតិដុល ដោយមិនរាប់បញ្ចូលមាសនិងទុនបម្រុងជា SDR គិតដល់ដំណាច់ខែធ្នូ ឆ្នាំ២០០៦ បានកើនឡើង ២២,៤៤% បើធៀបនឹងឆ្នាំ២០០៥ ។

ចំពោះប្រតិបត្តិការជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ IMF វិញ ចាប់ពីឆមាសទី១ ឆ្នាំ២០០៦ មក ធនាគារជាតិនៃកម្ពុជាពុំមានកាតព្វកិច្ចត្រូវសងរំលស់បំណុលទៀតឡើយ ដោយសារមូលនិធិរូបិយវត្ថុអន្តរជាតិបានសម្រេចលុបចោលបំណុល PRGF ចំនួន ៥៦,៨លានSDR កាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០០៦ ។ រីឯកាតព្វកិច្ចចំណាយសងលើបន្ទុកសុទ្ធ SDR និងការវាយតម្លៃ SDR ចំនួន ៥៤០,៩១៨SDR វិញ បច្ចុប្បន្នកម្ពុជាបានផ្ទេរសងគ្រប់ចំនួនហើយ ។

ក្នុងឆ្នាំ២០០៦ នេះ គណៈកម្មាធិការទីផ្សារចំហ (FOMC) បានបង្កើនអត្រាការប្រាក់គោល (Target Rate) ជាបន្តបន្ទាប់ចំនួន ៤ដង ធ្វើឱ្យអត្រាការប្រាក់ដុល្លារអាមេរិក (Fed Fund Rate) បានកើនពី ៤,២៥% ដល់ ៥,២៥% ហើយនៅទ្រឹងត្រឹមកម្រិតនេះ ចាប់តាំងពីដើមត្រីមាសទី ៣ មក ។ ទន្ទឹមនេះដែរ ធនាគារកណ្តាលអឺរ៉ុបបានតម្លើងអត្រាការប្រាក់អឺរ៉ូបានចំនួន ៥លើក ពី ២,២៥% ទៅ ៣,៥% ហើយធនាគារកណ្តាលអង់គ្លេសបានតម្លើងអត្រាការប្រាក់ផោនចំនួន ២លើក ពី ៤,៥០% ទៅ ៥% រីឯធនាគារកណ្តាលអូស្ត្រាលីវិញ ក៏បានតម្លើងអត្រាការប្រាក់របស់ខ្លួនចំនួន ៣លើកដែរ គឺពី ៥,៥០% ទៅ ៦,២៥% ។ ប្រការនេះបានធ្វើឱ្យអត្រាការប្រាក់ទទួលបានពីប្រតិបត្តិការ Overnight ប្រែប្រួល

ក្នុងរង្វង់ពី ៤,១១% ទៅ ៥,២៦% អត្រាការប្រាក់ពីការវិនិយោគលើប័ណ្ណរតនាគារអាមេរិកប្រែប្រួលក្នុងរង្វង់ ៣,៨៧% ទៅ ៥,១២% អត្រាការប្រាក់បញ្ញើរយៈកាលខ្លីជាប្រាក់ដុល្លារអាមេរិកប្រែប្រួលក្នុងរង្វង់ ៤,០៩% ទៅ ៥,៤៤% ដោយឡែកអត្រាការប្រាក់អឺរ៉ូប្រែប្រួលក្នុងរង្វង់ ២,២០% ទៅ ៣,៣១% អត្រាការប្រាក់ផោនប្រែប្រួលក្នុងរង្វង់ ៤,៣៨% ទៅ ៥,១២% និងអត្រាការប្រាក់ដុល្លារអូស្ត្រាលីប្រែប្រួលក្នុងរង្វង់ ៥,៧៥% ទៅ ៦,៣៣% ។ ឥទ្ធិពលនៃការបង្កើនអត្រាការប្រាក់របស់ធនាគារកណ្តាលផ្សេងៗ បានធ្វើឱ្យការវិនិយោគទទួលបានលទ្ធផលល្អប្រសើរ បើធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០០៥ កន្លងមក ។

### ៤.២. អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់

នៅក្នុងឆ្នាំ២០០៦ ដោយសារស្ថានភាពអត្រាប្តូរប្រាក់នៅលើទីផ្សារមានស្ថិរភាពល្អ ការធ្វើអន្តរាគមន៍នៅលើទីផ្សារ តាមរយៈការលក់ដេញថ្លៃប្រាក់ដុល្លារអាមេរិកពុំត្រូវបានអនុវត្តឡើយ ។ ផ្ទុយទៅវិញ ធនាគារជាតិនៃកម្ពុជាបានទិញប្រាក់ដុល្លារអាមេរិកបានចំនួន ៣៣លើក ដែលមានទឹកប្រាក់សរុបចំនួន ៤៦,៦២លានដុល្លារ ដោយចំណាយប្រាក់រៀលអស់ចំនួន ១៩០,៧៦ពាន់លានរៀល ។

### ៤.៣. ការគ្រប់គ្រងអាជីវកម្មមាស និងប្តូរប្រាក់

ក្នុងឆ្នាំ២០០៦ ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មលក់មាសនៅរាជធានីភ្នំពេញមានចំនួនសរុប ៥៥២ច្បាប់ ក្នុងនោះអាជីវកម្មប្តូរប្រាក់មានចំនួន ៥៣ច្បាប់ ។ រីឯនៅតាមខេត្ត-ក្រុង ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មលក់មាស និងប្តូរប្រាក់មានចំនួនសរុប ៣.៧៣៨ច្បាប់ ។

## ៥. សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

### ៥.១. ការត្រួតពិនិត្យធនាគារពាណិជ្ជ

ធនាគារជាតិនៃកម្ពុជានៅតែបន្តបណ្តុះបណ្តាល កសាង និងអភិវឌ្ឍសមត្ថភាពដល់មន្ត្រី-បុគ្គលិក ដើម្បីបង្កើនការអនុវត្តការងារឱ្យមានប្រសិទ្ធភាព និងតម្លាភាពទាំងក្នុងការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងការពិនិត្យតាមដានការអនុវត្តប្រកាស បទបញ្ជា សារាចរណែនាំ ដែលបានចេញផ្សាយផងដែរ ។

ធនាគារជាតិនៃកម្ពុជាក៏បានចេញផ្សាយ " របាយការណ៍ត្រួតពិនិត្យធនាគារពាណិជ្ជប្រចាំឆ្នាំ២០០៥ " (Annual Report Banking Supervision 2005) ដែលបានបង្ហាញអំពីតួលេខសរុបមួយចំនួនរបស់ប្រព័ន្ធធនាគារនៅកម្ពុជា សម្រាប់ជាប្រយោជន៍ដល់សាធារណជន និងបង្ហាញអំពីមុខងារ-ភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការធ្វើយ៉ាងណាឱ្យប្រព័ន្ធធនាគារមានសុវត្ថិភាព និងសុខភាពល្អ ដើម្បីជំរុញការអភិវឌ្ឍគ្រឹះស្ថានធនាគារក្នុងប្រទេស និងជាពិសេសការពារផលប្រយោជន៍ដល់អ្នកដាក់ប្រាក់បញ្ញើ ។

### ៥.១.១. ការត្រួតពិនិត្យលើឯកសារ

ការត្រួតពិនិត្យសកម្មភាពប្រតិបត្តិការរបស់ធនាគារត្រូវបានអនុវត្តជាប្រចាំ ដើម្បីពិនិត្យលើការអនុវត្តរបស់ធនាគារឱ្យស្របតាមច្បាប់ បទបញ្ជាប្រុងប្រយ័ត្ន និងត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ និងរកឱ្យឃើញសកម្មភាពប្រតិបត្តិការណាដែលមានភាពមិនប្រក្រតី ល្មើស ដើម្បីមានវិធានការកែតម្រូវ ព្រមាន និងដាក់ពិន័យ ។ ការត្រួតពិនិត្យជាចម្បងផ្តោតលើភាពគ្រប់គ្រាន់នៃដើមទុន អនុបាតសាធនភាព ហានិភ័យឥណទាន ការធ្វើសវិធានធន ប្រសិទ្ធភាពនៃទ្រព្យសកម្ម ស្ថានភាពប្រាក់ចំណេញ ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល និងការគ្រប់គ្រងអចលនវត្ថុ ។

ជាទូទៅស្ថានភាពធនាគារភាគច្រើនមានលក្ខណៈល្អ មានតែធនាគារមួយចំនួនតូចប៉ុណ្ណោះ ដែលនៅមានចំណុចខ្វះខាតមិនទាន់អនុវត្តបានទាំងស្រុងតាមច្បាប់ និងបទបញ្ជាប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា ដូចជា : ឱនភាពមូលនិធិផ្ទាល់សុទ្ធ ការកាន់កាប់អចលនទ្រព្យលើសកម្រិតកំណត់ ។ល។ ចំណុចខ្វះខាតទាំងនេះត្រូវបានចាត់វិធានការឱ្យធនាគារទាំងនោះ ធ្វើការកែតម្រូវជាបន្តបន្ទាប់ឱ្យស្របតាមបទបញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ។

ទន្ទឹមនឹងនេះដែរ ធនាគារជាតិនៃកម្ពុជាកំពុងបន្តរៀបចំប្រព័ន្ធបណ្តាញកុំព្យូទ័រ និងបានដាក់ឱ្យអនុវត្តសាកល្បងផ្នែកខ្លះនៃប្រព័ន្ធ COBRA (Cambodian Offsite Bank Reporting for Prompt Corrective Actions) ជាបណ្តើរៗ ។ ជាលទ្ធផលបណ្តោះអាសន្នឃើញថា ប្រព័ន្ធនេះមានប្រសិទ្ធភាពជាងប្រព័ន្ធធ្វើដោយដៃ ដោយជួយសម្រួលការងារជាច្រើនដល់អ្នកត្រួតពិនិត្យ ដូចជា ផ្តល់ពេលវេលាច្រើនសម្រាប់ធ្វើការវិភាគលើស្ថានភាពធនាគារនីមួយៗ ។

### ៥.១.២. ការត្រួតពិនិត្យដល់ទីកន្លែង

ក្នុងឆ្នាំ២០០៦ នេះ ធនាគារជាតិនៃកម្ពុជាបានសម្រេចដាក់ចេញនូវផែនការ ដើម្បីអនុវត្តការងារត្រួតពិនិត្យដល់ទីកន្លែងតាមវិសាលភាពពេញលេញ CAMELS លើធនាគារពាណិជ្ជចំនួន ១០ និងធនាគារឯកទេសចំនួន ២ ។

ជាលទ្ធផល ធនាគារជាតិនៃកម្ពុជាបានអនុវត្តសម្រេចទៅតាមផែនការដែលបានគ្រោងទុកលើធនាគារពាណិជ្ជចំនួន ១០ ដែលក្នុងនោះមានសាខាធនាគារបរទេសចំនួន ២ និងធនាគារឯកទេសចំនួន ២ ផងដែរ ។ ទន្ទឹមនេះដែរ ធនាគារជាតិនៃកម្ពុជាក៏បានអនុវត្តការងារជាបន្ទាន់និងចាំបាច់ ចំពោះការងារត្រួតពិនិត្យតាមមុខសញ្ញាលើធនាគារពាណិជ្ជ និងធនាគារឯកទេសចំនួន ៧ និងការត្រួតពិនិត្យពិសេសចំពោះធនាគារពាណិជ្ជចំនួន ២ បន្ថែមទៀត ។ ការត្រួតពិនិត្យនៅតែអនុវត្តបន្តចំពោះការពិនិត្យ និងតាមដានការអនុវត្តប្លង់គណនីឯកភាព ដើម្បីឱ្យស្របទៅនឹងគោលការណ៍គណនេយ្យនៃស្តង់ដារគណនេយ្យជាតិ និងអន្តរជាតិ ។ ការត្រួតពិនិត្យដល់ទីកន្លែងក៏ត្រូវបានធ្វើផងដែរ លើការអនុវត្តកាតព្វកិច្ចប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

ការងារត្រួតពិនិត្យដល់ទីកន្លែង សំដៅតាមដានរាល់ប្រតិបត្តិការអាជីវកម្មរបស់គ្រឹះស្ថានឱ្យបានស៊ីជម្រៅ ព្រមទាំងវាយតម្លៃពីភាពពិតប្រាកដ និងត្រឹមត្រូវជាក់លាក់នៃរបាយការណ៍ ដោយបានផ្តោតយ៉ាងខ្លាំងទៅលើការអនុវត្តឱ្យស្របតាមច្បាប់ និងបទបញ្ញត្តិនានា ដើម្បីការពារហានិភ័យផ្សេងៗ ។ រាល់ចំណុចខ្វះខាតដែលបានរកឃើញនៅក្នុងការត្រួតពិនិត្យត្រូវបានផ្តល់អនុសាសន៍ និងវិធានការចាំបាច់ ដើម្បីផ្តល់ឱកាសឱ្យសាមីធនាគារចាប់អនុវត្តកែតម្រូវបន្ទាន់ ។

## ៥.២. ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ឆ្នាំ២០០៦ ជាព្រឹត្តិការណ៍យ៉ាងសំខាន់សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ។ ជាក់ស្តែងនាឱកាសសន្និសីទជាតិស្តីពីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា កាលពីថ្ងៃទី ១១-១៣ ខែមករា ឆ្នាំ២០០៦ ដែលបានរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា សហការជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីបានប្រកាសជាផ្លូវការថា ឆ្នាំ២០០៦ ជាឆ្នាំមីក្រូហិរញ្ញវត្ថុកម្ពុជា ។ ការប្រារព្ធធ្វើសន្និសីទនេះដើម្បីទទួលស្គាល់ និងអបអរសាទរចំពោះការសម្រេចបានដ៏ជោគជ័យនៃវិស័យមីក្រូហិរញ្ញវត្ថុ ដែលជាគំនិតផ្តួចផ្តើមនៃវិស័យឯកជនក្នុងការចូលរួមកាត់បន្ថយភាពក្រីក្រ និងអនុញ្ញាតឱ្យមានការយល់ដឹងកាន់តែច្បាស់អំពីការប្រឈម សារៈសំខាន់នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងតួនាទីសំខាន់នៃវិស័យហិរញ្ញវត្ថុក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ បន្ទាប់ពីសន្និសីទជាតិ ធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និសីទតំបន់នៅខេត្តចំនួន ៣ គឺ ខេត្តបាត់ដំបង ខេត្តកំពត និងខេត្តកំពង់ចាម ដោយមានសមាជិកចូលរួមប្រមាណ ២០០០នាក់ តំណាងមកពីមន្ទីរជុំវិញខេត្ត អាជ្ញាធរមូលដ្ឋានខេត្ត-ក្រុង គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ អតិថិជនមីក្រូហិរញ្ញវត្ថុ និងមជ្ឈដ្ឋានផ្សេងៗទៀត ដើម្បីជំរុញការផ្សព្វផ្សាយដល់សាធារណជន និងអាជ្ញាធរមូលដ្ឋាន ចំពោះតួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងការគ្រប់គ្រងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងចំពោះការវិវត្តនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ព្រមទាំងតួនាទីមីក្រូហិរញ្ញវត្ថុក្នុងការកាត់បន្ថយភាពក្រីក្រ និងទាក់ទាញបាននូវការចូលរួមពីសំណាក់អង្គការជាតិនិងអន្តរជាតិ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍតាមរយៈការផ្តល់ហិរញ្ញប្បទាន និងហិរញ្ញប្បទានសម្រាប់បច្ចេកទេស ហើយម្យ៉ាងទៀត ដើម្បីធានាថា អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី នាសន្និសីទជាតិនោះត្រូវបានប្រែក្លាយទៅជាសកម្មភាពអនុវត្ត ។

ក្នុងឆ្នាំ២០០៦ នេះ សកម្មភាពមីក្រូហិរញ្ញវត្ថុមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ។ តាមការវិភាគលើរបាយការណ៍បានបង្ហាញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានផ្តល់ឥណទានសរុបចំនួនប្រមាណ ៣៥៦,៥ពាន់លានរៀល កើនឡើងប្រមាណ ៨១% បើប្រៀបធៀបជាមួយឆ្នាំ២០០៥ ដែលមានឥណទានសរុបចំនួន ១៩៦,៧ពាន់លានរៀល និងផ្តល់ដល់អតិថិជនប្រមាណ ៤៦៤.១២២នាក់ កើនឡើងប្រមាណ ២៧% បើប្រៀបធៀបឆ្នាំ២០០៥ ដែលមានអតិថិជនប្រមាណ ៣៦៦.១០៧នាក់ ។ ទន្ទឹមនេះ គ្រឹះស្ថានបានទទួលប្រាក់បញ្ញើប្រមាណ ១២,២៤ពាន់លានរៀល កើនឡើង ៥៤% និងមានអ្នកផ្ញើប្រាក់ចំនួន ១១៧.០០០នាក់ ថយចុះ ១៦% ដោយសារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនបានងាកពីការផ្តល់ឥណទានជាក្រុមមកជាឯកជនវិញ ។

ចំពោះអត្រាការប្រាក់ឱ្យខ្ចីវិញ ក៏មានការថយចុះជាបន្តបន្ទាប់ ចាប់ពីឆ្នាំ២០០០ មក ពោលគឺថយចុះពី ៥% ទៅ ៦% ក្នុង ១ខែ មកនៅត្រឹម ២% ទៅ ២,៥% ក្នុង ១ខែ ជាមធ្យមនៅឆ្នាំ២០០៦ នេះ ។

ក្នុងអំឡុងឆ្នាំ២០០៦ ធនាគារជាតិនៃកម្ពុជាបានចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១២ និងសមាគមដែលបានដាក់ពាក្យចុះបញ្ជីជាប្រតិបត្តិករឥណទានជនបទចំនួន ២ ។ លទ្ធផលនៃការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែងបានបង្ហាញឱ្យឃើញជាទូទៅថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថិតក្នុងស្ថានភាព

ល្អប្រសើរ ដោយគ្រឹះស្ថានមួយចំនួនអាចស្វែងរកដៃគូវិនិយោគក្រៅប្រទេស និងអាចរក្សានិរន្តរភាពបាន ថ្វីបើគ្រឹះស្ថានខ្លះត្រូវបានផ្តល់អនុសាសន៍ ឱ្យធ្វើការកែលំអនូវជំនាញក្នុងការវិភាគឥណទាន ការចុះកិច្ចបញ្ជិកាគណនេយ្យ និងការវិភាគហានិភ័យជាដើម ។

ជាបណ្តើរៗ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋមានការយល់ដឹងកាន់តែច្រើនអំពីវិស័យមីក្រូហិរញ្ញវត្ថុ និងអំពីផលប្រយោជន៍នៃការប្រើប្រាស់ប្រភពហិរញ្ញប្បទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬអង្គការក្រៅរដ្ឋាភិបាលសម្រាប់បង្កើតមុខរបរ ពង្រីកអាជីវកម្ម ឬបង្កើតសហគ្រាសខ្នាតតូច ដែលអាចបង្កើនប្រាក់ចំណូល និងបង្កើនការងារ ។

## ៥.៣. ការជម្រះបញ្ជីធនាគារដែលបានបិទទ្វារ

ធនាគារជាតិនៃកម្ពុជាជាអ្នកបន្តប្តឹងភាគទុនិកធនាគារដែលមិនអាចបន្តសកម្មភាពបាន រួមមាន ធនាគារក្រៅប្រទេសទី ១ ចំកាត់ ធនាគារកសិករកម្ពុជាចំកាត់ ធនាគារវិជណែស្បិណ ធនាគារសន្តិភាពពាណិជ្ជចំកាត់ និងធនាគារពាណិជ្ជកម្មនិងកសិកម្មនៃកម្ពុជាចំកាត់ និងប្តឹងទាមទារពីកូនបំណុលរបស់ធនាគារដែលនៅសេសសល់ដើម្បីយកប្រាក់មកទូទាត់សងម្ចាស់ប្រាក់បញ្ញើ ។ ជាលទ្ធផលក្នុងឆ្នាំ២០០៦នេះ ធនាគារក្រៅប្រទេសទី ១ ចំកាត់ បានប្រមូលប្រាក់ពីកូនបំណុល និងរឹបអូសអចលនទ្រព្យលក់ឡាយឡុងទទួលបានលទ្ធផលល្អប្រសើរ ដែលអាចមានលទ្ធភាពទូទាត់សងម្ចាស់ប្រាក់បញ្ញើចំនួន ៦៥% ថែមទៀត ដូច្នេះ បើគិតមកដល់ពេលនេះ សងបានជាង ៨០% នៃប្រាក់បញ្ញើអតិថិជនសរុប ហើយចំពោះធនាគារចំនួន ៤ ទៀត ពុំមានលទ្ធផលល្អទេ ។

## ៥.៤. ការងាររៀបចំបទបញ្ញា

ក្នុងឆ្នាំ២០០៦ នេះ ធនាគារជាតិនៃកម្ពុជាក៏បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីភតិសន្យា និងប្រកាសស្តីពីប្រព័ន្ធចែករំលែកព័ត៌មានឥណទានផងដែរ ។

ក្នុងឆ្នាំ២០០៦ នេះ ប្រកាសនិងបទបញ្ញត្តិមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត និងធ្វើវិសោធនកម្ម :

- ប្រកាសស្តីពីការកែសម្រួលប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ
- ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេស
- ប្រកាសស្តីពីការកែសម្រួលប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- ប្រកាសស្តីពីការកែសម្រួលប្រកាសស្តីពីកាលបរិច្ឆេទនៃការផ្ញើរបាយការណ៍របស់ធនាគារពាណិជ្ជ និងធនាគារឯកទេស
- ប្រកាសស្តីពីកាលបរិច្ឆេទនៃការផ្ញើរបាយការណ៍របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- ប្រកាសស្តីពីសោហ៊ុយនៃការបង្កើនដើមទុនសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- ប្រកាសស្តីពីការត្រួតពិនិត្យហានិភ័យនៃឥណទានធំៗ របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។

## ៦. ការផ្គត់ផ្គង់សេវាធនាគារកណ្តាល

### ៦.១. សេវាផ្នែកគណនី

ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងគណនីស្ថាប័នរដ្ឋ អង្គការរដ្ឋបាលកណ្តាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលទទួលបានការអនុញ្ញាតឱ្យធ្វើអាជីវកម្ម និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ។ សរុបគណនីទាំងអស់មានចំនួន ១.០៩១គណនីដែលជារូបិយវត្ថុជាតិ និងរូបិយប័ណ្ណដុល្លារអាមេរិក ។ ប្រតិបត្តិការសរុបក្នុងឆ្នាំ២០០៦ មានចំនួន ១៩៧.៧៤៥ប្រតិបត្តិការពោលគឺមានការកើនឡើង ៨% បើធៀបទៅនឹងឆ្នាំ២០០៥ ដែលមានចំនួន ១៨២.៨៦១ប្រតិបត្តិការ ។

#### ៦.១.១. សេវាផ្នែកគណនីចំពោះស្ថាប័នរដ្ឋ

ធនាគារជាតិនៃកម្ពុជាក៏បានរួមចំណែកក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើនប្រសិទ្ធភាពកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយទទួលបើកគណនីជូនស្ថាប័នរដ្ឋបាលកណ្តាល គ្រប់គ្រងនិងចាត់សម្រួលសាច់ប្រាក់តាមរយៈការបង្វែរប្រាក់ពីរតនាគារជាតិ ទៅរតនាគារខេត្ត-ក្រុង និងពីរតនាគារខេត្ត-ក្រុងមករតនាគារជាតិវិញ ជំនួសឱ្យការដឹកជញ្ជូនសាច់ប្រាក់ និងបើកប្រាក់បៀវត្សជូនមន្ទីរ-ក្រសួង និងកងកម្លាំងប្រដាប់អាវុធ ។

ការបង់ពន្ធដោយផ្ទាល់នៅធនាគារជាតិនៃកម្ពុជាពីសំណាក់អ្នកជាប់ពន្ធ បានប្រព្រឹត្តទៅដោយរលូនមានបរិមាណសរុប ៦៦៨,៩ពាន់លានរៀល (គិតទាំងចំណូលជាប្រាក់រៀលនិងជាប្រាក់ដុល្លារអាមេរិក) ។

#### ៦.១.២. ការទារអនុវត្តហិរញ្ញប្បទាន និងកម្ចីរដ្ឋាភិបាល

ក្នុងបណ្តាកម្ចីរបស់រាជរដ្ឋាភិបាល មានតែហិរញ្ញប្បទានពីរដ្ឋាភិបាលជប៉ុនប៉ុណ្ណោះ ដែលត្រូវបានប្រើប្រាស់ឆ្លងតាមរយៈធនាគារជាតិនៃកម្ពុជា ។

ក្នុងឆ្នាំ២០០៦ រដ្ឋាភិបាលជប៉ុនបានផ្តល់ដល់រាជរដ្ឋាភិបាលកម្ពុជា នូវហិរញ្ញប្បទានឥតសំណងចំនួន ៨គម្រោង (រួមទាំងហិរញ្ញប្បទានក្រៅគម្រោង ១ ផង) រួមមាន : គម្រោងកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍន៍សម្ភារៈបោសសំអាតមីនគម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស គម្រោងសិក្សាវិស្វកម្មលំអិតវារីអគ្គិសនីធុនតូច គម្រោងពង្រីកផ្លូវជាតិលេខ ១ គម្រោងផ្គត់ផ្គង់ទឹកស្អាតតំបន់ដាច់ស្រយាលខេត្តកំពង់ចាម និងគម្រោងផ្តល់ម៉ាស៊ីនត្រួតពិនិត្យទំនិញដល់កំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ។ ហិរញ្ញប្បទានសម្រាប់គម្រោងខាងលើ និងហិរញ្ញប្បទានឥតសំណងក្រៅគម្រោងមានទឹកប្រាក់សរុបចំនួន ៩.០៨២លានយ៉េន ក្នុងនោះបានប្រើប្រាស់អស់ចំនួន ២.២៩៣លានយ៉េន ហើយទឹកប្រាក់ដែលនៅសល់នឹងត្រូវបន្តប្រើប្រាស់រហូតដល់ឆ្នាំ២០១០ ។

ក្នុងឆ្នាំ២០០៦ នេះដែរ រដ្ឋាភិបាលជប៉ុនបានផ្តល់កម្ចីសម្បទានចំនួន ៣១៨លានយ៉េនបន្ថែមទៀត សម្រាប់អភិវឌ្ឍកំពង់ផែក្រុងព្រះសីហនុ ។

### ៦.១.៣. សេវាផ្នែកគណនីចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

គណនីដែលធនាគារពាណិជ្ជបានបើកនៅធនាគារជាតិនៃកម្ពុជារួមមាន គណនីចរន្ត គណនីប្រាក់បញ្ញើមានកាលកំណត់ គណនីប្រាក់បញ្ញើធានាលើដើមទុន និងគណនីប្រាក់បម្រុងកាតព្វកិច្ច ។

ប្រាក់បញ្ញើមានកាលកំណត់រយៈពេល១ខែ ៣ខែ ៦ខែ មានចំនួនសរុប ២៤១,៩លានដុល្លារអាមេរិក ។

## ៦.២. សេវាផាត់ទាត់

ប្រតិបត្តិការទូទាត់តាមរយៈសភាផាត់ទាត់បានដំណើរការប្រកបដោយប្រសិទ្ធភាព និងមានប្រតិបត្តិការជារៀងរាល់ថ្ងៃធ្វើការ ទាំងការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀលនិងជាប្រាក់ដុល្លារអាមេរិក ។

ការប្រើប្រាស់មូលប្បទានប័ត្រមាននិន្នាការរីកចម្រើនជាបណ្តើរៗ ជាពិសេសក្នុងមជ្ឈដ្ឋានធនាគារពាណិជ្ជ និងអង្គភាពរដ្ឋ។

### ៦.២.១. ការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល

សភាផាត់ទាត់មូលប្បទានប័ត្រជាប្រាក់រៀលមានសមាជិកចំនួន ១៦ ដែលរួមមាន ធនាគារពាណិជ្ជចំនួន ១៣ រតនាគារជាតិ ធនាគារឯកទេស ១ និងធនាគារជាតិនៃកម្ពុជា ។

ការផាត់ទាត់បានដំណើរការចំនួន ២៣៩ថ្ងៃ មានមូលប្បទានប័ត្រចំនួន ២០.០៥០សន្លឹក ដែលមានទឹកប្រាក់សរុបចំនួន ៦៨២ពាន់លានរៀល ។ សកម្មភាពផាត់ទាត់ក្នុងឆ្នាំ២០០៦ នេះ មានការកើនឡើងទាំងចំនួនមូលប្បទានប័ត្រ ទាំងចំនួនទឹកប្រាក់ បើធៀបទៅនឹងឆ្នាំ២០០៥ កន្លងមកនេះ ពោលគឺកើនពី ១៨.០៧៨សន្លឹក ទៅ ២០.០៥០សន្លឹក និងទឹកប្រាក់កើនពី ៥០២,៨៣ពាន់លានរៀល ទៅ ៦៨២ពាន់លានរៀល ។

### ៦.២.២. ការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់ដុល្លារអាមេរិក

សភាផាត់ទាត់មូល្បទានប័ត្រជាប្រាក់ដុល្លារអាមេរិកមានសមាជិកចំនួន ១៩ ដែលជាធនាគារពាណិជ្ជចំនួន ១៥ ធនាគារឯកទេស ៣ និងធនាគារជាតិនៃកម្ពុជា ។

សកម្មភាពនៃការផាត់ទាត់ឆ្នាំ២០០៦ បានដំណើរការចំនួន ២៣៩ថ្ងៃ មានការកើនឡើងទាំងចំនួនមូលប្បទានប័ត្រ និងចំនួនទឹកប្រាក់ បើធៀបទៅនឹងឆ្នាំ២០០៥ គឺពី ១៩៩.៨៤៧សន្លឹក ទៅ ២៦០.៣២៧សន្លឹក កើនឡើង ៣០% និងទឹកប្រាក់កើនពីចំនួន ១,៨១៨លានដុល្លារអាមេរិក ទៅ ២.៨៩៤លានដុល្លារអាមេរិក កើនឡើង ៥៩% ។

មូលប្បទានប័ត្រដែលបានយកមកផាត់ទាត់ជាមធ្យមក្នុងមួយថ្ងៃ ជាប្រាក់ដុល្លារអាមេរិក មានចំនួន ១.០៨៩ សន្លឹក ស្មើនឹងទឹកប្រាក់ប្រមាណជាង ១២លានដុល្លារអាមេរិក ជាប្រាក់រៀលមានចំនួន ៨៤សន្លឹក ស្មើនឹងទឹកប្រាក់ ២.៨៥៥លានរៀល ។

## ៦.៣. ការផ្តល់ឥណទាន

ក្នុងឆ្នាំ២០០៦ ធនាគារជាតិនៃកម្ពុជាបានផ្តល់ឥណទាន និងប្រមូលបំណុលមកវិញដូចខាងក្រោម :

- ធនាគារអេស៊ីលីដា : ឥណទានសរុបចំនួន ៤០ពាន់លានរៀល ប្រមូលបំណុល ១៦ពាន់លានរៀល សមតុល្យ ២៤ពាន់លានរៀល
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត : សមតុល្យដើមឆ្នាំ ១០,៥ពាន់លានរៀល ឥណទានសរុប ៣៨,៥ពាន់លានរៀល ប្រមូលបំណុល ២៩,៥ ពាន់លានរៀល សមតុល្យចុងឆ្នាំ ១៩,៥ពាន់លានរៀល
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ៤៧២,៥លានយ៉េន សម្រាប់សងបំណុល ODA ជប៉ុន (បំណុលចាស់មុនឆ្នាំ១៩៧០) ។

កម្រៃការប្រាក់សរុបប្រមូលបានពីបំណុលជាប្រាក់រៀលមានចំនួន ១.៨៤១,៨លានរៀល បំណុលជាប្រាក់ដុល្លារអាមេរិកបានចំនួន ៣៥.១១០ដុល្លារ ។

## ៧. ការគ្រប់គ្រងចរាចរណ៍ធនបត្រ

បច្ចុប្បន្នចរន្តលំហូរចូល-ចេញនៃសាច់ប្រាក់តាមរយៈប្រព័ន្ធគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឆ្លងកាត់បេឡាប្រតិបត្តិការរបស់ធនាគារជាតិនៃកម្ពុជា មានការកើនឡើងជាលំដាប់ ។ ជាក់ស្តែងក្នុងឆ្នាំ២០០៦ នេះ ចំណូលសាច់ប្រាក់តាមបេឡាប្រតិបត្តិការសរុបចំនួន ១.៧៣០,២ពាន់លានរៀល បើប្រៀបធៀបនឹងគ្រាដូចគ្នាឆ្នាំ២០០៥ កើនលើស ៦០% ។ ក្នុងនោះប្រាក់បញ្ញើចរន្តរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងក្រសួងស្ថាប័នរដ្ឋមានចំនួន ៥០៣,៦ពាន់លានរៀល កើនឡើង ៣៤% និងសាច់ប្រាក់បង់ពន្ធ-ពន្ធគយបញ្ចូលគណនីប្រាក់បញ្ញើចរន្តរបស់រតនាគារជាតិចំនួន ៦៩៥,៦ ពាន់លានរៀល កើនឡើង ៨៨% បើប្រៀបធៀបនឹងឆ្នាំ២០០៥ ។ រីឯចំណាយបេឡាប្រតិបត្តិការវិញ សរុបមានចំនួន ១.៩៩៨,៦ពាន់លានរៀល ។ បើប្រៀបធៀបនឹងគ្រាដូចគ្នាក្នុងឆ្នាំ២០០៥ កើនលើស ៦១% ។ ក្នុងនោះ ប្រាក់ចំណាយបើកឱ្យរតនាគារជាតិ បៀវត្សរ៍ក្រសួង ថវិកាឃុំ សង្កាត់ មានចំនួនសរុប ៧១៧,៥ពាន់លានរៀល កើន ៨១% បើប្រៀបធៀប ឆ្នាំ២០០៥ ។

ក្រៅពីចរន្តប្រព័ន្ធលំហូរចេញ-ចូលនៃក្រដាសប្រាក់រៀលឆ្លងកាត់បេឡា ធនាគារជាតិនៃកម្ពុជាបានជំរុញឱ្យបណ្តាសាខាខិតខំប្រមែប្រមូលក្រដាសប្រាក់ចាស់ៗ ដោយបញ្ចេញក្រដាសប្រាក់ថ្មីផ្តល់ឱ្យសម្រាប់ដូរក្រដាសប្រាក់ចាស់ៗ ពិសេសក្នុងឱកាសបុណ្យចូលឆ្នាំនិងភ្ជុំបិណ្ឌ នៅតាមទីផ្សារធំៗក្នុងរាជធានីភ្នំពេញ ។ សកម្មភាពផ្គត់ផ្គង់ក្រដាសប្រាក់ថ្មីសម្រាប់ដូរយកក្រដាសប្រាក់ចាស់ៗខូចគុណភាពពីចរាចរណ៍មកវិញ បានធ្វើឱ្យក្រដាសប្រាក់ក្នុងចរាចរណ៍មានលក្ខណៈថ្មីស្អាតល្អ និងកាន់តែជំរុញឱ្យសាធារណជនមានចំណង់ប្រើប្រាស់ប្រាក់រៀលកាន់តែច្រើនឡើង ។

ក្នុងឆ្នាំ២០០៦ នេះ ប្រាក់ក្លែងក្លាយមានសកម្មភាពថយចុះច្រើន បើប្រៀបធៀបនឹងឆ្នាំកន្លងទៅ ។ ក្រដាសប្រាក់រៀលក្លែងក្លាយដែលចាប់បានកន្លងមក ភាគច្រើនជាក្រដាសប្រាក់ថតចម្លងពណ៌ ហើយចាប់បានតាមរយៈបេឡាធនាគារជាតិនៃកម្ពុជា ។ ធនាគារជាតិនៃកម្ពុជាក៏បានធ្វើការណែនាំដល់អតិថិជនឱ្យស្គាល់ពីលក្ខណៈសំខាន់ៗដែលខុសគ្នារវាងក្រដាសប្រាក់ពិត និងក្រដាសប្រាក់ក្លែងក្លាយ ព្រមទាំងសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមានសមត្ថកិច្ចស្វែងរកជនលួចក្លែងបន្លំប្រើប្រាស់ក្រដាសប្រាក់ក្លែងក្លាយមកផ្តន្ទាទោសតាមផ្លូវច្បាប់ ។

## ៨- ការងារគ្រប់គ្រងមូលប័ត្រ

ផ្អែកតាមការជូនដំណឹងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានរៀបចំការដេញថ្លៃប័ណ្ណរតនាគាររយៈពេល ៩១ថ្ងៃ ចំនួន២លើក ដែលមានចំនួនប្រាក់សរុប ៩,៨ពាន់លានរៀល បានសងវិញចំនួន ៣លើក ដែលមានចំនួនប្រាក់ ១៣,៨ពាន់លានរៀល ។ ក្នុងឆ្នាំ២០០៦ ប័ណ្ណរតនាគារដែលបានចេញផ្សាយត្រូវបានទូទាត់អស់ទាំងស្រុង ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានកាត់បន្ថយសមតុល្យចាប់ពីខែមេសា ឆ្នាំ២០០៥ មក ។

ចាប់ពីដំណើរការដេញថ្លៃលើកដំបូងថ្ងៃទី ៤ ខែមេសា ឆ្នាំ២០០៣ មកដល់ដំណាច់ឆ្នាំ២០០៦ នេះ ប័ណ្ណរតនាគារត្រូវបានចេញផ្សាយចំនួន ៣៣លើក ព្រមទាំងបានសងវិញចំនួន ៣៣លើក ដែលមានទឹកប្រាក់សរុប ៤៧២,៩ពាន់លានរៀល ។

# II- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

## ១- សកម្មភាពក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជានាពេលបច្ចុប្បន្នមានសមាសភាពដូចខាងក្រោម :

- ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាប្រធាន
- លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ជាសមាជិក
- ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន តំណាងប្រមុខរាជរដ្ឋាភិបាល ជាសមាជិក
- ឯកឧត្តម អ៊ីវ ថុង តំណាងមជ្ឈដ្ឋានឧត្តមសិក្សា ជាសមាជិក
- ឯកឧត្តម ជូ គឹមឡេង តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក
- លោក ឡាយ ម៉េងស៊ុន តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច ជាសមាជិក
- លោកស្រី ម៉ៅ សុន តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា ជាសមាជិក ។

ក្នុងឆ្នាំ២០០៦ នេះ ក្រុមប្រឹក្សាភិបាលបានប្រជុំចំនួន ៦ លើក ដោយបានលើកយកបញ្ហាចម្បងៗដែលពាក់ព័ន្ធនឹងដំណើរការនៃការងាររបស់ធនាគារជាតិនៃកម្ពុជាមកពិភាក្សា ហើយបានអនុម័តលើការងារមួយចំនួនដូចខាងក្រោម :

- កិច្ចប្រជុំលើកទី ៥៤ នាថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យរបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០០៥

- កិច្ចប្រជុំលើកទី ៥៥ នាថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០៦ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ ថវិកាឆ្នាំ២០០៥ និងផែនការថវិកាឆ្នាំ២០០៦ របស់ធនាគារជាតិនៃកម្ពុជា

- កិច្ចប្រជុំលើកទី ៥៦ នាថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០៦ :

    - ពិភាក្សាអំពីបញ្ហាបំណុលរបស់រាជរដ្ឋាភិបាល
    - ពិភាក្សាអំពីការងាររៀបចំរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និង
    - ពិភាក្សាអំពីរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ។

- កិច្ចប្រជុំលើកទី ៥៧ នាថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៦ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ ប្រចាំឆមាសទី ១ និងទិសដៅសម្រាប់ឆមាសទី ២ ឆ្នាំ២០០៦ របស់ធនាគារជាតិនៃកម្ពុជា

- កិច្ចប្រជុំលើកទី ៥៨ នាថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៦ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ ស្ថានភាពចំណូល-ចំណាយថវិកាឆមាសទី ១ ឆ្នាំ២០០៦ របស់ធនាគារជាតិនៃកម្ពុជា និង

- កិច្ចប្រជុំលើកទី ៥៩ នាថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០០៦ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ ប្រចាំ ឆ្នាំ២០០៦ និងទិសដៅសម្រាប់ឆ្នាំ២០០៧ របស់ធនាគារជាតិនៃកម្ពុជា ។

## ២. ការអភិវឌ្ឍធនធានមនុស្ស

### ២.១. ស្ថិតិមន្ត្រី-បុគ្គលិក

- ក្របខ័ណ្ឌធនាគារជាតិនៃកម្ពុជា (ទីស្នាក់ការកណ្តាល) ឆ្នាំ២០០៦ នេះ មានចំនួន ៧០៦រូប (ប្រុស ៣៩២រូប ស្រី ៣១៤រូប) ក្នុងនោះ មន្ត្រីរក្សាក្របខ័ណ្ឌបម្រើការងារនៅធនាគារពាណិជ្ជកម្មក្រៅប្រទេស មានចំនួន ៣រូប (ប្រុស២រូប ស្រី១រូប)

- ក្របខ័ណ្ឌសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង មានចំនួន ៣២៦រូប (ប្រុស ១៩៥រូប ស្រី ១៣១រូប) ។

ដូច្នេះ សរុបក្របខ័ណ្ឌមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេសនៅឆ្នាំ២០០៦ នេះ មានចំនួន ១០៣៣ រូប (ប្រុស ៥៨៧រូប ស្រី ៤៤៦រូប) បើប្រៀបធៀបជាមួយក្របខ័ណ្ឌ ចុងខែធ្នូ ឆ្នាំ២០០៥ ដែលមានចំនួន ៩៨៤ រូប (ប្រុស ៥៦៥រូប ស្រី ៤១៩រូប) គឺមានការប្រែប្រួលដូចតទៅ:

- ទីស្នាក់ការកណ្តាលថយចំនួន ៩រូប (ចូល ១៩រូប ចេញ ២៨រូប)

- សាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង កើនចំនួន ៥៨រូប ( ចូល ៦៨រូប ចេញ ១០រូប) ។

## ២.២. ការងារបណ្តុះបណ្តាល

ឈរលើស្មារតីលើកកម្ពស់ការកសាងសមត្ថភាពធនធានមនុស្សនៅឆ្នាំ២០០៦ នេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំវគ្គសុក្រឹតការចំនួន ១វគ្គ ( មន្ត្រី-បុគ្គលិកចូលរួមចំនួន ៧៣រូប) និងវគ្គណែនាំប្រតិបត្តិការចំពោះសាខាធនាគារជាតិនៃកម្ពុជាចំនួន ៣វគ្គ ( មន្ត្រី-បុគ្គលិកចូលរួមចំនួនសរុប ៩០រូប) សម្រាប់បំប៉នចំណេះដឹងមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា និងសាខាធនាគារជាតិនៃកម្ពុជា និងបានចាត់បញ្ជូនចូលរួមវគ្គវិក្រឹតការនៅសាលាភូមិន្ទរដ្ឋបាលចំនួន ១លើក ( មន្ត្រី ចូលរួមចំនួន ២រូប) គឺ :

- វគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ចំនួន ១រូប
- វគ្គវិក្រឹតការមន្ត្រីមធ្យមចំនួន ១រូប

និងសិក្ខាសាលាចំនួន ១១លើក នៅធនាគារជាតិនៃកម្ពុជា ( សរុបមន្ត្រី-បុគ្គលិកចូលរួមចំនួន ៣៧៨រូប) ។

ក្រៅពីការបើកវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា ធនាគារជាតិនៃកម្ពុជាក៏បានបញ្ជូនមន្ត្រី-បុគ្គលិកទៅចូលរួមក្នុងវគ្គសិក្សា និងសិក្ខាសាលាតាមការអញ្ជើញពីបណ្តាក្រសួង-ស្ថាប័ននានាផងដែរ ក្នុងនោះមានវគ្គបណ្តុះបណ្តាលចំនួន ៥លើក ( សរុបមន្ត្រី-បុគ្គលិកចូលរួមចំនួន ៨រូប) និងសិក្ខាសាលាចំនួន ៧លើក មានមន្ត្រី-បុគ្គលិកចូលរួមចំនួន ៨០រូប ។

ទន្ទឹមនឹងនេះ ធនាគារជាតិនៃកម្ពុជាក៏បានបំផុសនិងជំរុញឱ្យមន្ត្រី-បុគ្គលិកនៅទីស្នាក់ការកណ្តាល និងនៅសាខាធនាគារជាតិនៃកម្ពុជា ខិតខំប្រឹងប្រែងលើកកម្ពស់ចំណេះដឹងដោយខ្លួនឯងថែមទៀត ទាំងចំណេះដឹងខាងបច្ចេកទេស ទាំងភាសាអង់គ្លេស ដើម្បីឱ្យស្របតាមសភាពការណ៍ថ្មីនៃការវិវត្ត និងការធ្វើសមាហរណកម្មសេដ្ឋកិច្ចជាតិទៅក្នុងសេដ្ឋកិច្ចតំបន់និងពិភពលោក ។

ចំពោះការងារបណ្តុះបណ្តាលនៅមណ្ឌលសិក្សាបច្ចេកទេសធនាគារក្នុងឆ្នាំ២០០៦ នេះ មាន :

- មន្ត្រី-បុគ្គលិកក្នុងប្រព័ន្ធធនាគារចូលរៀនចំនួន ៤០ នាក់
- រៀបចំការប្រឡងបញ្ចប់និស្សិតជំនាន់ទី១៤ ( ៨៤នាក់) និងប្រឡងបញ្ចប់ឆមាសជំនាន់ទី១៥ ( ១២៤នាក់)
- រៀបចំជ្រើសរើសនិស្សិតចូលរៀនជំនាន់ទី ១៦ បានចំនួន ១៤៤នាក់
- បើកបវេសនកាលថ្មីជំនាន់ទី ១៥ និង ១៦
- ទំនាក់ទំនងជាមួយក្រសួងអប់រំយុវជន និងកីឡា ធ្វើសញ្ញាប័ត្រប្រកាសនីយប័ត្រជាន់ខ្ពស់បច្ចេកទេសធនាគារ ដល់និស្សិតចំនួន ១៩៣នាក់
- រៀបចំពិធីប្រគល់សញ្ញាប័ត្រ នៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៦ ដល់និស្សិតជំនាន់ទី ១២ និង ១៣ សរុបចំនួន ១៩៣នាក់

ក្រៅពីការបណ្តុះបណ្តាលនៅក្នុងប្រទេស ធនាគារជាតិនៃកម្ពុជាក៏បានចាត់បញ្ជូនមន្ត្រី-បុគ្គលិករបស់ខ្លួនទៅចូលរួមវគ្គសិក្សារយៈពេលខ្លីនិងវែង ទស្សនកិច្ចសិក្សា និងសិក្ខាសាលាផ្សេងៗនៅក្រៅប្រទេស តាមរយៈការអញ្ជើញរបស់ស្ថាប័នអន្តរជាតិនានាផងដែរ ដូចជា ធនាគារកណ្តាលអាល្លឺម៉ង់ (Deutsche Bundesbank) មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) សហភាពអឺរ៉ុប (European Union) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារកណ្តាលកូរ៉េ (Bank of Korea) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) មជ្ឈមណ្ឌលអូស្ត្រាលី (AUSTRAC) ក្រសួងហិរញ្ញវត្ថុចិន (MOF, China) ធនាគារស្វីស (Gerzensee Bank) ក្រុមហ៊ុនអាល្លឺម៉ង់ Iwent ក្រុមហ៊ុនអាល្លឺម៉ង់ JOHS RIECKERMANN (JR) ក្រសួងហិរញ្ញវត្ថុនៃសាធារណរដ្ឋកូរ៉េ (MEF, Korea) ក្រុមហ៊ុនម៉ាឡេស៊ី (Gold Quest Ltd.) ក្រុមហ៊ុនកូរ៉េ KADO សាធារណរដ្ឋប្រជាមានិតចិន (People’s Republic of China), Bank for International Settlements (BIS) អង្គការផ្តល់ជំនួយអាមេរិក (USAID) ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) មជ្ឈមណ្ឌលហិរញ្ញវត្ថុ និងអភិវឌ្ឍន៍អាស៊ី ប៉ាស៊ីហ្វិក (AFDC) មជ្ឈមណ្ឌល SEACEN ធនាគារកណ្តាលឥណ្ឌូណេស៊ី ធនាគារកណ្តាលថៃ ធនាគារកណ្តាល ម៉ាឡេស៊ី រដ្ឋាភិបាលឥណ្ឌា អាជ្ញាធររូបិយវត្ថុសិង្ហបុរី（MAS）ក្រុមអាស៊ីប៉ាស៊ីហ្វិក（Asia Pacific Group (APG)）និងសមាគមឥណទានកសិកម្មនិងឥណទានជនបទតំបន់អាស៊ីប៉ាស៊ីហ្វិក（Asia-Pacific Rural and Agriculture Credit Association (APRACA)）។

## ៣. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

ក្នុងឆ្នាំ២០០៦ នេះ ធនាគារជាតិនៃកម្ពុជាបានធ្វើកំណែទម្រង់រចនាសម្ព័ន្ធរបស់អគ្គាធិការដ្ឋាន សំដៅពង្រឹងការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចឱ្យមានប្រសិទ្ធភាព ដែលជំហានដំបូង គឺការរៀបចំនូវលិខិតបទដ្ឋានចាំបាច់នានា ដូចជា សៀវភៅនីតិវិធីសវនកម្មសម្រាប់នាយកដ្ឋាន សាខា និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ។

បន្ទាប់ពីបានរៀបចំសម្រួលរចនាសម្ព័ន្ធ និងកំណត់នូវតួនាទីនិងភារកិច្ចរបស់មន្ត្រី-បុគ្គលិកជាសវនករ និងមន្ត្រីអធិការកិច្ចមក ការងារបណ្តុះបណ្តាលក៏បានធ្វើឡើង ដើម្បីបំពាក់បំប៉នសមត្ថភាពតាមរយៈការបណ្តុះបណ្តាលជាទ្រឹស្តីចុះហាត់ការងារ និងការបញ្ជូនទៅបណ្តុះបណ្តាលនៅក្រៅប្រទេស ។

សៀវភៅនីតិវិធីសវនកម្មសម្រាប់នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានបោះផ្សាយ-ឃ្លាំងបេឡា និងសាខាធនាគារជាតិនៃកម្ពុជា ត្រូវបានរៀបចំនិងកែសម្រួលជាបន្តបន្ទាប់ ដើម្បីធ្វើឱ្យនីតិវិធីទាំងនោះអាចតម្រូវតាមស្ថានភាពបច្ចុប្បន្ន និងធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រតិបត្តិការរបស់នាយកដ្ឋាន និងអង្គភាពទាំងនោះ ។

បន្ទាប់មក សៀវភៅនីតិវិធីប្រតិបត្តិការសម្រាប់នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងនាយកដ្ឋាន អង្គភាពផ្សេងទៀត ក៏ត្រូវរៀបចំជាបន្តបន្ទាប់ ដើម្បីឈានទៅដល់ការមាននូវក្រិត្យក្រមច្បាស់លាស់សម្រាប់ធ្វើសវនកម្ម ។

សម្រាប់ការងារសវនកម្ម នាយកដ្ឋានដែលទទួលការធ្វើសវនកម្មមុនគេ តាមវិធីសាកល្បង និងហ្វឹកហាត់ការងារ គឺនាយកដ្ឋានប្រតិបត្តិការ ការិយាល័យគ្រប់គ្រងគណនី នាយកដ្ឋានបោះផ្សាយ-ឃ្លាំងបេឡា ការិយាល័យបេឡា និង ការិយាល័យគណនេយ្យជំនួយ និងការចុះបញ្ជីនៅនាយកដ្ឋានគណនេយ្យ ព្រមទាំងសាខាខេត្តសៀមរាប ។ បន្ទាប់ពីការ ធ្វើសវនកម្ម របាយការណ៍រួមជាមួយអនុសាសន៍មួយចំនួនត្រូវបានដាក់ចេញដើម្បីធ្វើការកែលំអ ។

ចំពោះការងារអធិការកិច្ចវិញ ក៏ត្រូវបានដំណើរការយ៉ាងមមាញឹក តាមរយៈការចុះទៅធ្វើអធិការកិច្ចដោយមិន ជូនដំណឹងមុនចំនួន ២០លើក លើសាខាចំនួន ១៥ លើការងារគ្រប់គ្រងសាច់ប្រាក់ និងកិច្ចការពារសុវត្ថិភាពឃ្លាំងប្រាក់ ហើយព័ត៌មានស្ដីពីលំហូរសាច់ប្រាក់នៅនាយកដ្ឋានបោះផ្សាយ-ឃ្លាំងបេឡាក៏ត្រូវបានរៀបចំឡើង និងសេចក្តីណែនាំថ្មី អំពីការចុះបញ្ជីកន្ទុយសាច់ប្រាក់ដែលអតិថិជនមិនបានបើក ការកាន់កាប់ និងរក្សាទុកកូនសោឃ្លាំង ក៏កំពុងត្រូវបានរៀបចំ ។

## ៤. ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា

ក្នុងឆ្នាំ២០០៦ សកម្មភាពរបស់បណ្ដាញសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង កាន់តែត្រូវបានពង្រឹងពង្រីក ថែមទៀត ជាពិសេសក្នុងវិស័យការងារសាច់ប្រាក់ ដើម្បីលើកកម្ពស់សមត្ថភាពជំនាញ និងការទទួលខុសត្រូវក្នុងកិច្ច សហការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយវិមជ្ឈការរបស់រាជរដ្ឋាភិបាល តាម រយៈការបើកគណនីបម្រើអតិថិជនមានចំនួនឡើងដល់ប្រមាណ ១.២២០គណនី គឺកើនចំនួន ៨% បើធៀបនឹងឆ្នាំមុន ដែលក្នុងនោះ មានគណនីរបស់អង្គភាពសាធារណៈចំនួន ៤៦២គណនី ។ ក្រៅពីនេះ បណ្ដាញសាខានៅបានបំពេញ តួនាទីសំខាន់ជាទីភ្នាក់ងាររបស់ធនាគារកណ្ដាល ក្នុងការផ្គត់ផ្គង់សេវាកម្មជូនគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ អង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិនៅតាមតំបន់ ដែលអាចទូទាត់សងគ្នាតាមមូលប្បទានប័ត្រ និង ធ្វើការផ្ទេរប្រាក់នៅក្នុងតំបន់ ឬទៅមករវាងរាជធានីភ្នំពេញនិងខេត្ត-ក្រុង ។

## ៥. ការងារគណនេយ្យធនាគារជាតិនៃកម្ពុជា

ឆ្នាំ២០០៦ នេះ ទ្រព្យសកម្មធនាគារជាតិនៃកម្ពុជាបានកើនឡើងជាង ១.៤០១ពាន់លានរៀល គឺ ១៧,៩៦% ក្នុងនោះកំណើនដែលគួរឱ្យកត់សម្គាល់ គឺប្រាក់បញ្ញើជារូបិយប័ណ្ណនៅស្ថាប័នហិរញ្ញវត្ថុ និងធនាគារបរទេស ដែលមាន កំណើនសរុប ៦៨១ពាន់លានរៀល ពោលគឺកើន ២៩,២២% និងការវិនិយោគលើមូលប័ត្របានកើនឡើង ១២២ ពាន់លានរៀល ពោលគឺកើនឡើង ៨,២៦% ប៉ុន្តែសាច់ប្រាក់ជារៀល និងរូបិយប័ណ្ណមានការថយចុះ ៦ពាន់លានរៀល គឺ ថយចុះ ១,៩៥% ។ ចំណែកផ្នែកទ្រព្យអកម្មវិញ រូបិយវត្ថុបានបោះផ្សាយមានកំណើន ៣២៤ពាន់លានរៀល ពោលគឺ កើន ២១,៤១% ហើយប្រាក់បញ្ញើរបស់រដ្ឋាភិបាលមានកំណើន ៤១៤ពាន់លានរៀល គឺស្មើនឹង ៦១,៣៧% ចំណែក ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជមានការកើនឡើងចំនួន ៤១៤ពាន់លានរៀល គឺស្មើនឹង ២៨,៨៦% ។

# តារាងតុល្យការធនាគារជាតិនៃកម្ពុជា

ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៦

## ទ្រព្យសកម្ម

(ឯកតាលានរៀល)

| អត្ថាធិប្បាយ | ចំនួនទឹកប្រាក់<br>ថ្ងៃ ៣១ ខែធ្នូ ឆ្នាំ ២០០៥ | ចំនួនទឹកប្រាក់<br>ថ្ងៃ ៣១ ខែធ្នូ ឆ្នាំ ២០០៦ |
|---|---:|---:|
| សាច់ប្រាក់ជារៀល និងជារូបិយប័ណ្ណ | ៣១៥.៧៧៦ | ៣០៩.៦២៨ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ នៅធនាគារបរទេស | ២.៣៣០.៦៤៣ | ៣.០១១.៦៩១ |
| ប្រាក់ SDR នៅមូលនិធិរូបិយវត្ថុអន្តរជាតិ | ៩៧៩ | ៧៦៣ |
| ប្រាក់រៀលបង់ចូលជាសមាជិកមូលនិធិរូបិយវត្ថុអន្តរជាតិ | ៥៣៦.៩៧៨ | ៥២៧.២២៩ |
| វិនិយោគលើមូលប័ត្របរទេស | ១.៤៨១.៧៦០ | ១.៦០៤.០៥៥ |
| លោហធាតុមានតម្លៃ ផ្ញើនៅបរទេស | ៨៤៩.១៤៤ | ១.០៣១.៩៥១ |
| ឱ្យខ្ចី និងបុរេប្រទាន | | |
| - ចំពោះធនាគារពាណិជ្ជ | ១០.៥២០ | ៤៣.៥២០ |
| - ចំពោះរដ្ឋាភិបាល | ២៧០.៤០៩ | ២៧០.២៩៣ |
| អចលនទ្រព្យ | ២៦៨.៨៩២ | ៤១០.៧៩១ |
| ផ្សេងៗ | ១.៧៣៦.០៣៨ | ១.៩៩២.៣៩៤ |
| **សរុប** | **៧.៨០១.១៣៩** | **៩.២០២.៣១៥** |

## ទ្រព្យអកម្ម

(ឯកតាលានរៀល)

| អត្ថាធិប្បាយ | ចំនួនទឹកប្រាក់ | ចំនួនទឹកប្រាក់ |
|---|---:|---:|
| រូបិយវត្ថុបោះផ្សាយ | ១.៥១៣.២៨៨ | ១.៨៣៧.៣១១ |
| ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ | ១.៤៣៣.៤៣៨ | ១.៨៤៧.១៨៩ |
| បំណុលចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ | ៩៦៨.០៧១ | ៦២៨.៧២៤ |
| ប្រាក់បញ្ញើរបស់រដ្ឋាភិបាល | ៦៧៥.២០០ | ១.០៨៩.៥៤៨ |
| ដើមទុន | ១០០.០០០ | ១០០.០០០ |
| ទុនបម្រុង | ១.១៩០.៤៦៦ | ១.៤០៩.៩៥៩ |
| រំលស់បង្គរទុក | ៦៦.០៥៥ | ៧៨.០២៩ |
| សវិធានធន | ៩៥.០១៣ | ១៤៥.៨៨៨ |
| ផ្សេងៗ | ១.៧៥៩.៦០៨ | ២.០៦៥.៦៦៧ |
| **សរុប** | **៧.៨០១.១៣៩** | **៩.២០២.៣១៥** |

## III. ទំនាក់ទំនងអន្តរជាតិ

### ១. ទំនាក់ទំនងពហុភាគី

#### ១.១. ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ

នៅក្នុងអំឡុងឆ្នាំ២០០៦ នេះ មូលនិធិរូបិយវត្ថុអន្តរជាតិបានផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា ដើម្បីពង្រឹងសវនកម្មផ្ទៃក្នុង ពង្រឹងការវិភាគលើប្រាក់កម្ចីនិងឥណទាន ការជួយរៀបចំក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុ ការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃប្រភពទិន្នន័យស្ថិតិរូបិយវត្ថុ និងស្ថិតិជញ្ជីងទូទាត់ពង្រឹងការងារប្រតិបត្តិការធនាគារកណ្តាល និងសភាផាត់ទាត់ ក៏ដូចជាការផ្តួចផ្តើមបណ្តុះបណ្តាលសមត្ថភាពផ្នែកប្រព័ន្ធទូទាត់ និងការរៀបចំសេចក្តីព្រាងប្រកាសចំនួន៤ សម្រាប់អនុវត្តច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។ ទន្ទឹមនោះ ក្រុមបេសកកម្មនៃមាត្រា IV និងនាយកប្រតិបត្តិ SEA-Group ក៏បានអញ្ជើញមកធ្វើការងារជាមួយដៃគូកម្ពុជាផងដែរដើម្បី (ក) ពិនិត្យជាមួយរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជាលើការអនុវត្តក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនាពេលកន្លងទៅនេះ និង (ខ) ពិនិត្យនិងរៀបចំមូលដ្ឋានសម្រាប់ផ្តល់ឥណទានក្រោមកម្មវិធីកំណើននិងកាត់បន្ថយភាពក្រីក្រថ្មីមួយ (PRGF) ។ បច្ចុប្បន្ន ដំណើរការ PRGF ថ្មីនេះ ត្រូវជួបនឹងការរាំងស្ទះមួយរយៈ ដោយសារបញ្ហាបំណុលដក់សល់ជាមួយអតីតសហភាពសូវៀតពុំទាន់មានដំណោះស្រាយសមស្រប ប៉ុន្តែមូលនិធិរូបិយវត្ថុអន្តរជាតិសន្យានឹងជួយជ្រោមជ្រែងលើចំណុចនេះ និងបន្តផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេសជាធម្មតា ។

យោងតាមកិច្ចពិភាក្សានាកន្លងមកនេះ បេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិបានវាយតម្លៃយ៉ាងខ្ពស់លើដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្ពុជា អំពីការអនុវត្តម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជានៅឆ្នាំ២០០៥ ដែលមានលក្ខណៈប្រសើរខ្លាំងជាងការគ្រោងទុក ពោលគឺផលិតផលក្នុងស្រុកសរុបមានកំណើនរហូតដល់ ១៣,៤% ធៀបនឹង ១០% នៅឆ្នាំ២០០៤ ខណៈដែលអតិផរណាស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ហើយទុនបម្រុងអន្តរជាតិបានបន្តកើនឡើង ។

កាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០០៦ នៅក្រោមកម្មវិធីស្តីពី "គំនិតផ្តួចផ្តើមកាត់បន្ថយបំណុលជាពហុភាគី " ប្រទេសកម្ពុជាបានទទួលនូវការលុបបំណុលចោល ១០០% ដែលស្មើនឹងទឹកប្រាក់ចំនួន ៥៦,៨លានSDR (៨២លានដុល្លារអាមេរិក) ទៅលើបំណុលដែលជំពាក់មូលនិធិរូបិយវត្ថុអន្តរជាតិមុនថ្ងៃទី ១ ខែមករា ឆ្នាំ២០០៥ ។ រហូតមកដល់ពេលនេះ ប្រទេសកម្ពុជាពុំមានជាប់ជំពាក់បំណុលមូលនិធិរូបិយវត្ថុអន្តរជាតិទៀតទេ ។

#### ១.២. ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី

នៅក្នុងរយៈពេលកន្លងមកនេះ ធនាគារអភិវឌ្ឍន៍អាស៊ី បានផ្តល់ការទ្រទ្រង់ជាច្រើនចំពោះកំណែទម្រង់ស្ថាប័ននិងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងវិស័យធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា ។

បន្ទាប់ពីច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ បានទទួលការអនុម័តពីរដ្ឋសភារួច កាលពីខែកញ្ញា ឆ្នាំ២០០៥ កន្លងមកនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ីរៀបចំ

សិក្ខាសាលា ដើម្បីផ្សព្វផ្សាយនិងបណ្តុះបណ្តាលដល់មន្ត្រីធនាគារ គ្រឹះស្ថានសិក្សា ស្ថាប័នពាក់ព័ន្ធ និងសាធារណជនឱ្យយល់ដឹងកាន់តែច្បាស់អំពីច្បាប់នេះ ។ ប្រកាសចំនួនបីក៏ត្រូវបានដាក់ឱ្យប្រើប្រាស់ហើយដែរ ។ ចំណែកសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក៏ត្រូវបានរៀបចំរួច និងបានដាក់ជូនរដ្ឋសភាពិនិត្យអនុម័ត ហើយបច្ចុប្បន្ននេះ ធនាគារជាតិនៃកម្ពុជាកំពុងធ្វើការកែលំអប្រកាស បទបញ្ញត្តិមានស្រាប់ ដើម្បីសម្របតាមច្បាប់ថ្មីនេះ ។

ក្រៅពីនេះ ទាក់ទិននឹងកម្មវិធីអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម ក្រុមការងារធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារជាតិនៃកម្ពុជាក៏បានរៀបចំចប់សព្វគ្រប់នូវក្របខ័ណ្ឌគតិយុត្ត និងបទបញ្ញត្តិនានាដែលចាំបាច់សម្រាប់ដំណើរការដោយរលូននៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានហើយដែរ ។ ផ្អែកទៅលើលទ្ធផលទាំងនោះ នៅថ្ងៃទី ៩ ខែសីហា ឆ្នាំ ២០០៦ ធនាគារជាតិនៃកម្ពុជា ដោយសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ក៏បានរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធចែករំលែកព័ត៌មានឥណទាននោះ ។ ដោយឡែក ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុវិញ កំពុងដំណើរការទៅមុខជាលំដាប់ ដែលគ្រោងនឹងបញ្ចប់នៅពេលឆាប់ៗខាងមុខ ។

នៅក្នុងឆ្នាំ២០០៦ នេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀត រៀបចំធ្វើបច្ចុប្បន្នកម្មឯកសារចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ឱ្យទៅជាឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥វិញ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួល និងការអភិវឌ្ឍនៃសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន និងទៅអនាគត ។

## ១.៣. ទំនាក់ទំនងជាមួយអាស៊ាន

ក្នុងដំណើរការសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន និងអាស៊ាន +៣ (ចិន កូរ៉េ ជប៉ុន) ធនាគារជាតិនៃកម្ពុជាចូលរួមចំណែកជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទទួលធ្វើជាម្ចាស់ផ្ទះ និងដឹកនាំការប្រជុំផ្សេងៗ សម្រាប់ឆ្នាំ២០០៦ ដូចជា ការប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ការប្រជុំថ្នាក់អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលរងអាស៊ាន និងអាស៊ាន +៣ និងការប្រជុំថ្នាក់ក្រុមការងារមន្ត្រីជំនាញផ្សេងៗស្តីពីការអភិវឌ្ឍទីផ្សារសញ្ញាប័ណ្ណ ការធ្វើសេរីភាវូបនីយកម្មគណនីដើមទុន និងសេវាហិរញ្ញវត្ថុ សហប្រតិបត្តិការហិរញ្ញវត្ថុតាមគំនិតផ្តួចផ្តើមឈៀងម៉ៃ ។ល។

ដើម្បីជំរុញសហប្រតិបត្តិការលើវិស័យហិរញ្ញវត្ថុរវាងធនាគារកណ្តាលនៅអាស៊ាន ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើមឱ្យមានការប្រជុំក្រៅផ្លូវការថ្នាក់ទេសាភិបាលអាស៊ាននៅប្រទេសសិង្ហបុរី កាលពីខែកញ្ញា ឆ្នាំ២០០៦ សំដៅពង្រឹងការងាររូបិយវត្ថុ ផ្សារភ្ជាប់ទៅនឹងក្របខ័ណ្ឌសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន ។

ចំពោះការបណ្តុះបណ្តាល និងកសាងសមត្ថភាព ធនាគារជាតិនៃកម្ពុជានៅបន្តស្វែងរកការឧបត្ថម្ភគាំទ្រពីប្រទេសសមាជិកក្នុងតំបន់ដែលមានការជឿនលឿន និងពីធនាគារអភិវឌ្ឍន៍អាស៊ី សំដៅលើកកម្ពស់សមត្ថភាពមន្ត្រី-បុគ្គលិក លើវិស័យវិភាគស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិសេសការកសាងប្រព័ន្ធផ្តល់ដំណឹងជាមុន (Early Warning System) ដែលកំពុងត្រូវបានសាកល្បងប្រើប្រាស់ជាបណ្តើរៗ ។

## ១.៤. ទំនាក់ទំនងជាមួយ SEACEN

នៅថ្ងៃទី ១ ខែមេសា ឆ្នាំ២០០៦ ក្រុមប្រឹក្សាភិបាលនៃ SEACEN (South-east Asia Central Bank) ក្នុងសន្និសីទថ្នាក់ទេសាភិបាល បានសម្រេចបញ្ចូលធនាគារជាតិនៃកម្ពុជាជាសមាជិកទី ១៥ របស់ខ្លួន ។ ការចូលជាសមាជិក SEACEN នេះ មិនត្រឹមតែអាចពង្រីកសហប្រតិបត្តិការល្អរវាងធនាគារកណ្តាលក្នុងតំបន់ប៉ុណ្ណោះទេ ថែមទាំងផ្តល់អត្ថប្រយោជន៍ដ៏ច្រើនដល់កម្ពុជា ដូចជា បទពិសោធន៍ល្អៗក្នុងការអនុវត្តនយោបាយរូបិយវត្ថុរបស់បណ្តាប្រទេសសមាជិក ការទទួលការបណ្តុះបណ្តាលធនធានមនុស្ស ការពង្រឹងគុណភាពការងារ និងការអភិវឌ្ឍវិស័យធនាគារទៀតផង ។

ទន្ទឹមនេះដែរ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយ SEACEN រៀបចំកិច្ចប្រជុំថ្នាក់ប្រធាននាយកដ្ឋានស្រាវជ្រាវ និងបណ្តុះបណ្តាលរបស់ SEACEN លើកទី ២៨ នៅខេត្តសៀមរាប កាលពីថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ដោយមានការចូលរួមពីប្រតិភូធនាគារកណ្តាលនៃប្រទេសសមាជិកទាំង ១៥ ប្រទេស ។

កិច្ចប្រជុំនេះបានសិក្សាស្វែងយល់ និងផ្លាស់ប្តូរបទពិសោធន៍លើបញ្ហាសំខាន់ៗមួយចំនួនដែលជាការងារអាទិភាពរបស់ធនាគារកណ្តាល ដូចជា ការគ្រប់គ្រងធនធានមនុស្សនៅធនាគារកណ្តាលឱ្យកាន់តែប្រសើរឡើង ការដឹកនាំនយោបាយរូបិយវត្ថុ និងការស្វែងរកវិធីសាស្រ្ត និងយន្តការតាមដានម៉ាក្រូសេដ្ឋកិច្ចជាដើម ។ ក្រៅពីនេះ អង្គប្រជុំក៏បានពិភាក្សា និងសម្រេចលើប្រធានបទសំខាន់ៗមួយចំនួនសម្រាប់ការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងវិស័យធនាគារ និងហិរញ្ញវត្ថុ និងសម្រាប់ធ្វើការបណ្តុះបណ្តាលមន្ត្រីជំនាញរបស់ធនាគារកណ្តាលជាសមាជិកទាំងអស់នៅឆ្នាំបន្ទាប់ ។

## ១.៥. ទំនាក់ទំនងជាមួយក្រុមអាស៊ីប៉ាស៊ីហ្វិក (APG)

ក្រុមអាស៊ីប៉ាស៊ីហ្វិកស្តីពីការសំអាតប្រាក់ (APG) ត្រូវបានបង្កើតឡើងនៅខែកុម្ភៈ ឆ្នាំ១៩៩៧ នៅក្នុងសន្និសីទអាស៊ីប៉ាស៊ីហ្វិកលើកទី ៤ ស្តីពីការសំអាតប្រាក់ នៅក្នុងទីក្រុងបាងកក ក្នុងគោលបំណងឆ្លើយតបថ្នាក់តំបន់ទៅនឹងការគំរាមកំហែងនៃការសំអាតប្រាក់ទូទាំងសកលលោក ។ ធនាគារជាតិនៃកម្ពុជាបានចូលជាសមាជិកក្រុមអាស៊ីប៉ាស៊ីហ្វិកនៅឆ្នាំ២០០៤ ដើម្បីពង្រឹងការអនុវត្តចំពោះកិច្ចការយូរអង្វែងលើទំនាក់ទំនងរវាងអំពើពុករលួយ និងការសំអាតប្រាក់ដែលជាបញ្ហាសំខាន់មួយនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក និងពិភពលោក ។ នាពេលបច្ចុប្បន្ន ការសំអាតប្រាក់មិនគ្រាន់តែជាបញ្ហាសម្រាប់ប្រព័ន្ធយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែជាបញ្ហាម៉ាក្រូសេដ្ឋកិច្ចផងដែរ ដោយសារតែវាអាចធ្វើឱ្យប្រព័ន្ធហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុពុំមានស្ថិរភាព ។

ធនាគារជាតិនៃកម្ពុជាបានទទួលកិច្ចសហប្រតិបត្តិការបច្ចេកទេសពីអង្គការអន្តរជាតិ និងសមាជិកក្រុមអាស៊ីប៉ាស៊ីហ្វិក ដើម្បីបណ្តុះបណ្តាល ពន្លឿនដំណើរការអនុវត្តបទដ្ឋានអន្តរជាតិសម្រាប់ប្រយុទ្ធប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។ ជាក់ស្តែង ប្រទេសកម្ពុជាត្រូវរងការវាយតម្លៃអញ្ញមញ្ញ (Mutual Evaluation) នៅដើមឆ្នាំ២០០៧ នេះ ក៏បានទទួលកិច្ចសហប្រតិបត្តិការបច្ចេកទេសពីការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងបទឧក្រិដ្ឋ (UNODC) ផងដែរ ។

### ១.៦. ទំនាក់ទំនងជាមួយសមាគមឥណទានកសិកម្ម និងឥណទានជនបទអាស៊ីប៉ាស៊ីហ្វិក (APRACA)

ធនាគារជាតិនៃកម្ពុជាបានចូលជាសមាជិកសមាគមឥណទានកសិកម្ម និងឥណទានជនបទអាស៊ីប៉ាស៊ីហ្វិក (APRACA) នៅឆ្នាំ២០០០ ក្នុងទិសដៅពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងផ្លាស់ប្តូរបទពិសោធន៍ បច្ចេកវិទ្យាទៅវិញទៅមក តាមរយៈការបណ្តុះបណ្តាលផ្នែកឥណទានកសិកម្មជនបទ និងការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ក្នុងនាមជាសមាជិកភាព ធនាគារជាតិនៃកម្ពុជាបានចូលរួមសកម្មភាពបណ្តុះបណ្តាលនានា ដែលរៀបចំដោយ APRACA ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ។

ជាក់ស្តែង នៅឆ្នាំ២០០៦ នេះ ធនាគារជាតិនៃកម្ពុជាបានបញ្ជូនមន្ត្រីចូលរួមប្រជុំគណៈកម្មការប្រតិបត្តិ (EXCOM) របស់ APRACA លើកទី៥១ នៅក្រុងហ្សាកាតា ដែលបានប្រព្រឹត្តទៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងឥណទានមានបញ្ហា ដែលបានប្រព្រឹត្តទៅនៅទីក្រុងសេឡាំងគ័រ ប្រទេសម៉ាឡេស៊ី និងវគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃហានិភ័យឥណទានកសិកម្ម ដែលបានប្រព្រឹត្តទៅនៅទីក្រុងបាងកក ។

## ២. ទំនាក់ទំនងទ្វេភាគី

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងទំនាក់ទំនងទ្វេភាគី ជាមួយបណ្តាប្រទេសជាមិត្ត ទាំងនៅក្នុងតំបន់អាស៊ីក៏ដូចជានៅអឺរ៉ុប-អូស្ត្រាលី លើគោលការណ៍នៃសហប្រតិបត្តិការជំនាញ ដូចជា ការផ្លាស់ប្តូរព័ត៌មាន និងការបណ្តុះបណ្តាលមន្ត្រីជាដើម ។

នៅក្នុងឆ្នាំ២០០៦ ធនាគារជាតិនៃកម្ពុជាបានធ្វើការផ្លាស់ប្តូរទស្សនកិច្ចសិក្សា ជាមួយប្រតិភូនៃធនាគារកណ្តាលចិន ធនាគារកណ្តាលថៃ និងធនាគារកណ្តាលអាល្លឺម៉ង់ ។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានជំរុញសហប្រតិបត្តិការជាមួយធនាគារកណ្តាលវៀតណាម ជាពិសេសធនាគារកសិកម្មវៀតណាម ក្នុងគោលបំណងជំរុញសហប្រតិបត្តិការធនាគារ និងការទូទាត់ឆ្លងព្រំដែននៃប្រទេសទាំងពីរ ។ ក្នុងឆ្នាំនេះដែរ ធនាគារជាតិនៃកម្ពុជាបានទទួលស្វាគមន៍ទស្សនកិច្ចជាមិត្តភាពរបស់ទេសាភិបាលធនាគារកណ្តាលបារាំង ធនាគារកណ្តាលបែលហ្ស៊ិក និងធនាគារកណ្តាលលុចហ្សំបួរ ព្រមទាំងបានចុះហត្ថលេខាលើអនុស្សរណៈសហប្រតិបត្តិការរវាងធនាគារកណ្តាលកម្ពុជាជាមួយធនាគារកណ្តាលប្រទេសបារាំងផងដែរ ។

## សន្និដ្ឋាន

ឆ្នាំ២០០៦ ត្រូវបានកត់សម្គាល់ដោយវឌ្ឍនភាពជាបង្គួរ និងបញ្ហាប្រឈមមួយចំនួនចំពោះសេដ្ឋកិច្ចពិភពលោក ដែលបានជះឥទ្ធិពលមួយផ្នែកមកលើប្រទេសកម្ពុជាដែរ ជាពិសេសគឺការឡើងថ្លៃប្រេងឥន្ធនៈ ។ ប៉ុន្តែទោះជាដូច្នេះក្តី កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានៅតែរក្សាបាននូវភាពល្អប្រសើរក្នុងឆ្នាំ២០០៦ នេះ ដោយមានកម្រិតលើស ពីមធ្យមភាគនៃរយៈកាល ១០ ឆ្នាំកន្លងមក ។ ជាមួយនឹងតម្រូវការបង្កើតកំណើនសេដ្ឋកិច្ច និងការរក្សាស្ថិរភាពថ្លៃ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់រក្សាស្ថិរភាពប្រាក់រៀលដែលត្រូវបានចាត់ទុកថា ជាឧបករណ៍ដ៏សំខាន់មួយនៃ ការអនុវត្តនយោបាយរូបិយវត្ថុ និងការជំរុញប្រើប្រាស់ប្រាក់រៀល ។ ជាលទ្ធផលនៃនយោបាយរូបិយវត្ថុនិងប្តូរប្រាក់ដ៏ប្រុង ប្រយ័ត្ន និងទន់ភ្លន់បត់បែនទាន់សភាពការណ៍ ទីផ្សារប្តូរប្រាក់មានការអភិវឌ្ឍដោយរលូន នៅពេលដែលអតិផរណាមាន កម្រិតមួយស្របតាមទិសដៅនៃផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍ (National Strategic Development Plan ) ហើយការផ្គត់ផ្គង់ទុនចំពោះប្រតិបត្តិការអាជីវកម្មក្នុងសេដ្ឋកិច្ចក៏មានការកើនឡើង ។ ទន្ទឹមនោះ សូចនាករ ម៉ាក្រូសេដ្ឋកិច្ចមួយចំនួនទៀត ក៏បានបង្ហាញនូវលទ្ធផលល្អផងដែរ ។ ក្នុងនោះ ការនាំចេញនិងវិនិយោគបរទេសបានរក្សា និន្នាការកើនឡើង ដែលបង្កើតនូវមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

ជាមួយនឹងស្ថានភាពដ៏ប្រសើរនៃម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងផងដែរ លើការលើកកម្ពស់កំណែទម្រង់រចនាសម្ព័ន្ធស្ថាប័ន និងច្បាប់ ។ ប្រព័ន្ធធនាគារត្រូវបានពង្រឹង និងអភិវឌ្ឍជាបន្ត ដោយបាន នាំមកនូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ជាច្រើន ក្នុងនោះរួមមានការអភិវឌ្ឍប្រព័ន្ធទូទាត់ និងផាត់ទាត់នៅកម្ពុជាឱ្យមាន ដំណើរការប្រសើរជាងមុន ការបង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ការរៀបចំសេចក្តីព្រាងបទបញ្ញត្តិសម្រាប់អនុវត្ត ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់ ការកែលំអស្តង់ដារបទបញ្ញត្តិ និងការដាក់ឱ្យប្រើនូវ បទបញ្ញត្តិធនាគារថ្មីៗមួយចំនួន រួមទាំងវិធានការពាក់ព័ន្ធនឹងការសំអាតប្រាក់ និងការប្រឆាំងហិរញ្ញប្បទានភេរវកម្ម ។ ទន្ទឹមនោះ ក៏មានការខិតខំជំរុញឱ្យសាធារណជនបានប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុទូលំទូលាយជាងមុនផងដែរ ។

លើសពីនេះទៀត ការរៀបចំសេចក្តីព្រាងនៃការធ្វើបច្ចុប្បន្នកម្ម " ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យ ហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ " ទៅជា " យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ " ដែលត្រូវបានបញ្ចប់ ថ្មីៗនេះ ក៏ជាសមិទ្ធផលមួយទៀតឆ្លុះបញ្ចាំងនូវវឌ្ឍនភាពថ្មីៗនៃការខិតខំរបស់ធនាគារជាតិនៃកម្ពុជា គួបផ្សំនឹងកិច្ច សហការពីស្ថាប័នពាក់ព័ន្ធជាដៃគូដទៃទៀតផងដែរ ។ ក្នុងគោលនយោបាយបង្កើនប្រសិទ្ធភាព ភាពរឹងមាំ និងស្ថិរភាព ជានិរន្តនៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ការពង្រឹងប្រតិបត្តិការផ្ទាល់របស់ធនាគារជាតិនៃកម្ពុជា ដែលជាអាជ្ញាធររូបិយវត្ថុ និងត្រួតពិនិត្យក៏ជាអាទិភាពសំខាន់មួយនៃកំណែទម្រង់ដែរ ។

ក្នុងនោះការយកចិត្តទុកដាក់ត្រូវបានផ្តោតទៅលើការបណ្តុះបណ្តាលមន្ត្រី-បុគ្គលិក ការពង្រឹងសមត្ថភាពត្រួត ពិនិត្យប្រព័ន្ធធនាគារ និងការងារពាក់ព័ន្ធនឹងប្រតិបត្តិការធនាគារកណ្តាលផ្សេងៗទៀត ក៏ដូចជាការរៀបចំនិងពង្រឹង រចនាសម្ព័ន្ធនិងមុខងាររបស់បណ្តាសាខាធនាគារជាតិខេត្ត-ក្រុង ។ លើសពីនេះធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងកិច្ច

សហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នជាតិ និងអន្តរជាតិ នឹងបានឈានទៅមុខជាលំដាប់ជាមួយនឹងការធ្វើកំណែទម្រង់ចាំបាច់ទាំងឡាយ ។

ដូចបានកំណត់នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥ ធនាគារជាតិនៃកម្ពុជា នៅមានការងារ និងបញ្ហាប្រឈមជាច្រើនទៀតដែលត្រូវដោះស្រាយ ហើយសមិទ្ធផលដែលទទួលបាននៅឆ្នាំ២០០៦នេះ នឹងផ្តល់សន្ទុះមួយថ្មីចំពោះការខិតខំនាឆ្នាំខាងមុខ ។ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា រាជរដ្ឋាភិបាលបានយល់ដឹងយ៉ាងច្បាស់ពីភាពចាំបាច់នៃការបង្កើនកំណើនសេដ្ឋកិច្ចដ៏ខ្ពស់ប្រកបដោយចីរភាព និងផ្អែកលើមូលដ្ឋានទូលំទូលាយ ដែលនឹងគ្រប់គ្រងដល់ការកាត់បន្ថយភាពក្រីក្រ និងវិសមភាពក្នុងសង្គម ។

# ខ-  ទិសដៅការងារឆ្នាំ២០០៧

## ទិសដៅការងារឆ្នាំ២០០៧

នៅក្នុងបរិការណ៍នេះ និងស្ថិតក្រោមសម្ពាធនៃបញ្ហាប្រឈមនានាទាំងក្នុងនិងក្រៅប្រទេស នៅឆ្នាំ២០០៧ សេដ្ឋកិច្ចត្រូវបានគ្រោងថា នឹងមានកំណើន ៧% ឯអត្រាអតិផរណាប្រចាំឆ្នាំត្រូវបានរំពឹងថា នឹងអាចរក្សាក្នុងកម្រិតប្រមាណ ៤% ហើយអត្រាប្តូរប្រាក់នឹងមានស្ថិរភាពសមស្របសម្រាប់សម្រួលដល់សកម្មភាពសេដ្ឋកិច្ច ។ ប៉ុន្តែ គួរកត់សម្គាល់ដែរថា កំណើនថ្លៃប្រេង ម្ហូបអាហារ និងជម្ងឺគ្រុនផ្តាសាយបក្សី នៅតែជាហានិភ័យចំពោះមុខ ចំពោះការព្យាករខាងលើ ។

ការចូលរួមចំណែកសម្រេចនូវទិសដៅសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល នៅចំពោះមុខហានិភ័យជាសក្តានុពលទាំងឡាយ គឺជាបញ្ហាប្រឈមសម្រាប់វិស័យធនាគារ ដែលទាមទារនូវការគ្រប់គ្រងឱ្យបានសមស្រប ។

ផ្អែកតាមលទ្ធផលដែលសម្រេចបានក្នុងឆ្នាំ២០០៦ នេះ ធនាគារជាតិនៃកម្ពុជាបានពិនិត្យឡើងវិញនិងកែសម្រួលនូវបណ្តាទិសដៅទាំងឡាយ ព្រមទាំងកំណត់ទិសដៅថ្មីសម្រាប់ឆ្នាំ២០០៧ ដូចខាងក្រោម :

### ១. ការងាររូបិយវត្ថុ

- កំណើនរូបិយវត្ថុទូទៅ (M2) ២០%
- កំណើនរូបិយវត្ថុក្នុងចរាចរណ៍ ១៦%
- កំណើនប្រាក់បញ្ញើជារូបិយប័ណ្ណ ២០%
- កំណើនទ្រព្យសកម្មបរទេសសុទ្ធ ១១%
- កំណើនទ្រព្យសកម្មក្នុងស្រុកសុទ្ធ ៤៣% ។

### ២. ការងារប្តូរប្រាក់

- បន្តធ្វើការសិក្សាលើការវិវត្តនៃអត្រាការប្រាក់របស់រូបិយប័ណ្ណសំខាន់ៗ
- ពង្រឹងការងារគ្រប់គ្រងអាជីវកម្មប្តូរប្រាក់ និងលោហធាតុត្បូងថ្មមានតម្លៃ
- បន្តការអភិវឌ្ឍប្រព័ន្ធផាត់ទាត់ និងទូទាត់ជាតិ ។

### ៣. ការងារត្រួតពិនិត្យ

- ពង្រឹងការអនុវត្តច្បាប់ បទបញ្ញាប្រុងប្រយ័ត្ន
- បន្តការអនុវត្តបណ្តាញកុំព្យូទ័រ COBRA ឱ្យបានពេញលេញ
- បន្តការអនុវត្តត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមវិសាលភាពពេញលេញ និងតាមមុខសញ្ញា

- បន្តជម្រះបញ្ជីធនាគារដែលបានបិទទ្វារ និងខិតខំប្រមែប្រមូលបំណុល ដើម្បីទូទាត់សងប្រាក់បញ្ញើអតិថិជន
- បន្តចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំ២០០៦ របស់នាយកដ្ឋានត្រួតពិនិត្យ ។

## ៤. ការងារគណនេយ្យ

- បន្តអនុវត្តគម្រោងកំណែទម្រង់ការងារគណនេយ្យ និងកែសម្រួលកម្មវិធីគណនេយ្យក្នុងប្រព័ន្ធកុំព្យូទ័រ ដែលកំពុងប្រើប្រាស់ឱ្យកាន់តែល្អប្រសើរ
- បូកសរុប និងធ្វើការវិភាគរបាយការណ៍គណនេយ្យឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា ។

## ៥. ការងារប្រតិបត្តិការ

- ពង្រឹងនិងត្រួតពិនិត្យការអនុវត្តការងារផាត់ទាត់មូលប្បទានប័ត្រចរឹកជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិកដើម្បីធានាគុណភាពទូទាត់ក្នុងប្រព័ន្ធធនាគារទាំងមូល
- បង្កើនកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការផ្តល់សេវាធនាគារជូនរាជរដ្ឋាភិបាល ក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រតិបត្តិការគ្រប់គ្រងគណនីតាមប្រព័ន្ធកុំព្យូទ័រឱ្យស្របតាមសំណូមពរការងារ និងរចនាសម្ព័ន្ធដែលមានការកែសម្រួល ។

## ៦. ការងារបោះផ្សាយ-ឃ្លាំងបេឡា

- បន្តពង្រឹងការងារគ្រប់គ្រងសាច់ប្រាក់នៅបេឡាប្រតិបត្តិការ និងថែរក្សាធនប័ត្រក្នុងឃ្លាំងឱ្យមានសុវត្ថិភាព
- បន្តពង្រឹងការងារដឹកជញ្ជូនសាច់ប្រាក់ផ្តល់ឱ្យសាខាធនាគារជាតិនៃកម្ពុជា ដោយរក្សាការសម្ងាត់ និងធានាសុវត្ថិភាព
- បន្តសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីរាំងខ្ទប់នូវការក្លែងបន្លំចាយប្រាក់ក្លែងក្លាយ ។

## ៧. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

- កែសម្រួលសៀវភៅស្តីពីនីតិវិធីសវនកម្មនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងខុទ្ទកាល័យធនាគារជាតិនៃកម្ពុជា និងរៀបចំសៀវភៅស្តីពីនីតិវិធីសវនកម្មនាយកដ្ឋានរោងពុម្ព
- ចុះធ្វើសវនកម្មនៅនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងធ្វើសវនកម្មនៅសាខាធនាគារជាតិនៃកម្ពុជាចំនួន ៦ ។
- ចុះធ្វើអធិការកិច្ចសាខាធនាគារជាតិនៃកម្ពុជាឱ្យបានយ៉ាងតិច ២ដង ក្នុងសាខានីមួយៗ និងឱ្យបានម្តងក្នុងនាយកដ្ឋាននីមួយៗនៅទីស្នាក់ការកណ្តាល

- បន្តជួយត្រួតពិនិត្យបណ្តាលិខិតបទដ្ឋាននានាដែលកំពុងនៅជាធរមាន ដើម្បីរួមសហការកែសម្រួល ឬធ្វើបច្ចុប្បន្នភាពឱ្យបានសមស្រប មានតម្លាភាព តាមស្ថានភាពជាក់ស្តែងបច្ចុប្បន្ន ។

## ៨. ការបណ្តុះបណ្តាល

- បន្តកិច្ចសហការលើការបណ្តុះបណ្តាលធនធានមនុស្សជាមួយនឹងស្ថាប័នជាតិ និងអន្តរជាតិ ។
- រៀបចំការប្រឡងបញ្ចប់និស្សិតជំនាន់ទី ១៥ និងប្រឡងបញ្ចប់ឆមាសនិស្សិតជំនាន់ទី ១៦
- ជ្រើសរើសនិស្សិតចូលរៀនជំនាន់ទី ១៧ និងបើកបវេសនកាលថ្មី ។

✧✧✧✧✧✧✧✧

# ឧបសម្ព័ន្ធ